ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

ព្រឹត្តិបត្រ ៨ ២០២៣ លេខ៦៩ ឆ្នាំទី១៧

# នារីរតនៈ

## NEARY RATTANAK NEWSLETTER



# អបអរសាទរ

# សម្រាប់បងប្អូនកម្មករ-កម្មការិនី
# ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង
# និងផលិតផលិតផលធ្វើដំណើរ និងកាបូប

ចេញផ្សាយដោយ នាយកដ្ឋានព័ត៌មាន នៃក្រសួងកិច្ចការនារី

info@mowa.gov.kh www.mowa.gov.kh facebook.com/mowa.gov.kh youtube.com/mowacambodiaofficial

## គណៈកម្មការត្រួតពិនិត្យ

លោកជំទាវ ប៊ុន ពុទ្ធី រដ្ឋលេខាធិការ

លោកជំទាវ ថងភៀន ផ័យម៉ាលី អនុរដ្ឋលេខាធិការ

ឯកឧត្តម ថេ ឈុនហាក់ អគ្គនាយក

លោកជំទាវ យិន សារ៉ាត់ ទីប្រឹក្សា

លោកស្រី ឪ រ៉ានី អគ្គនាយករង

## គណៈកម្មការនិពន្ធ និងក្រាហ្វិចកុំព្យូទ័រ

លោកស្រី ប៉ែន គន្ធា

លោកស្រី អ៊ុង ខេមរា

លោកស្រី ប្រាក់ សោភា

លោកស្រី ថា បូណារី

លោក ប៉ោង សុធី

លោក ប៉េង សុធីណា

លោកស្រី តែ សុខខេង

លោកស្រី មាស ពិសី

លោកស្រី ឆយ ឡាវី

លោកស្រី ពិន រើន

លោក អ៊ិន់ បុត្រ

លោក មឿន ឆេង

លោក សឿន វណ្ណារ៉ូ

លោក ហ៊ិត ចំរើន

លោក ប៉ែន ជា

កញ្ញា រិទ្ធិ ភារុន


# មាតិកា


-អបអរសាទរប្រាក់ឈ្នួលអប្បបរមា ឆ្នាំ២០២៤សម្រាប់បងប្អូន...០១

-សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី..............០២

-កិច្ចប្រជុំថ្នាក់ដឹកនាំលើកទី២០ នៃសមាគមជាតិកាកបាទ.........០៤

-សូមអបអរសាទរលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី .................០៦

-វេទិកាស្ត្រីចិន-អាស៊ានឆ្នាំ២០២៣ នៅទីក្រុងលីចូវ..................០៧

-វេទិកាលើកទី៣ ស្តីពីការអភិវឌ្ឍស្ត្រី និងកិច្ច..........................០៨

-កិច្ចសន្ទនាគោលនយោបាយអាស៊ាន សហភាពអឺរ៉ុប..............០៩

-សិក្ខាសាលាស្តីពី «ការពង្រឹងភាពធន់ និងភាពជាអ្នក..............១០

-ទិវាបុណ្យជាតិសាធារណរដ្ឋសិង្ហបុរីលើកទី៥៨.......................១៤

-ពិធីសម្តែងការគួរសម និងជម្រាបលារបស់អគ្គរដ្ឋទូត..............១២

-លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីក្រសួងកិច្ចការនារីអនុញ្ញាត.......១៣

-ពិធីបើកយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីជម្ងឺមហារីក........១៤

-ពិធីជួបពិភាក្សាការងារជាមួយឯកអគ្គរាជទូតជប៉ុន.................១៥

-លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី អនុញ្ញាតឱ្យបណ្តាញសហ........១៦

-លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីអនុញ្ញាតឱ្យសមាគមសហគ្រិន..១៧

-ពិធីប្រកាសបើកយុទ្ធនាការទិវាអន្តរជាតិក្មេងស្រី...................១៨

-កិច្ចប្រជុំពិគ្រោះយោបល់លើឯកសារផែនទីតំរង់ទិស..............១៩

-ពិធីបិទបញ្ចប់និងបូកសរុបលទ្ធផលរបស់គម្រោងសហគ្រិន.....២០

-វគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងរដ្ឋបាល.........................២១

-វគ្គបណ្តុះបណ្តាលសេរីទី២ ស្តីពី ការបង្កើតមាតិកាឌីជីថល......២២

-សិក្ខាសាលាស្តីពី ការឆ្លុះបញ្ចាំងនៃការអនុវត្តការងារ..............២៣

-វគ្គបណ្តុះបណ្តាលស្តីពី «ថវិកាសមិទ្ធកម្ម».............................២៤

-វគ្គបណ្តុះបណ្តាលស្តីពី ច្បាប់ និងឯកសារក្បួននីតិវិធី..............២៦

-សកម្មភាពការងាររបស់នាយកដ្ឋានផែនការ.........................២៧

-សកម្មភាពការងាររបស់នាយកដ្ឋានសមភាពយេនឌ័រ.............២៨

-សកម្មភាពការងាររបស់នាយកដ្ឋានសហប្រតិបត្តិការ.............២៩

-សកម្មភាពការងាររបស់នាយកដ្ឋានស្ត្រី និងសុខភាព.............៣០

-សកម្មភាពការងាររបស់នាយកដ្ឋាននាយកដ្ឋានព័ត៌មាន..........៣១

-សកម្មភាពការងាររបស់នាយកដ្ឋាននាយកដ្ឋានការពារផ្លូវ.......៣២

-សកម្មភាពការងាររបស់នាយកដ្ឋាននាយកដ្ឋានស្ត្រី និងការ....៣៣

-ស្នាដៃស្ត្រី .........................................................................៣៤-៤៥

ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# អបអរសាទរ

# ២០៤$

## ប្រាក់ឈ្នួលអប្បបរមា
## ឆ្នាំ២០២៤





សម្រាប់បងប្អូន
កម្មករ-កម្មការិនី
ផ្នែកវាយនភណ្ឌ កាត់ដេរ
ផលិតស្បែកជើង និងផលិត
ផលិតផលធ្វើដំណើរ និងកាបូប



# សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រ កម្ពុជា ជួបសំណេះសំណាលជាមួយបងប្អូនកម្មករចំនួន ១២.០៦០នាក់






កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២៣ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា អរគុណប្រជាពលរដ្ឋខេត្តកំពង់ចាម ដែលបានបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជា ខណៈ **សម្តេចធិបតី**អញ្ជើញជាអធិបតីពិធីជួបសំណេះសំណាលជាមួយបងប្អូន កម្មករចំនួន ១២.០៦០នាក់ នៅតាមបណ្តារោងចក្រ សហគ្រាសចំនួន ១៤ ដែលមានមូលដ្ឋានស្ថិតនៅក្នុងស្រុកព្រៃឈរ និងស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

**សម្តេចធិបតី ហ៊ុន ម៉ាណែត** បានថ្លែងថា ដោយសារសន្លឹកឆ្នោតរបស់ប្រជាពលរដ្ឋនេះហើយ ដែលផ្តល់ឱកាសឱ្យគណបក្សប្រជាជនកម្ពុជាបង្កើតរាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយរបស់ខ្លួនបន្តទៀត ។

សម្តេចបន្តថា ៤១ឆ្នាំហើយ ដែលគណបក្សប្រជាជនបានដឹកនាំប្រទេស បំរើប្រជាជន និងបន្តដឹកនាំទៅមុខទៀត ហើយ **សម្តេចធិបតី** បន្តថា មានតែការបោះឆ្នោតតាមរដ្ឋធម្មនុញ្ញទេ ដែលជាមធ្យោបាយសុវត្ថិភាពក្នុងការជ្រើសរើសមេដឹកនាំ មិនមែនជាការជ្រើសរើសតាមបែបបាតុកម្ម ដើម្បីផ្តួលរំលំរដ្ឋាភិបាលនោះទេ គឺការបោះឆ្នោតជាការសម្តែងមតិដែលផ្តល់ឱកាសដឹកនាំប្រទេស ។

ក្នុងនោះមានប្រជាពលរដ្ឋខេត្តកំពង់ចាមប្រមាណ



៥៥ម៉ឺននាក់បានទៅបោះឆ្នោត ហើយក្នុងនោះជាង ៩១ម៉ឺននាក់ បានបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជា ដែលបញ្ជាក់ថា បងប្អូនសប្បាយចិត្តបោះឆ្នោតគាំទ្រចំពោះគណបក្សប្រជាជនកម្ពុជា បន្តដឹកនាំប្រទេសជាតិ និងដើម្បីថែរក្សាសុខសន្តិភាព ៕ ***ដកស្រង់ពី AKP***



# កិច្ចប្រជុំថ្នាក់ដឹកនាំលើកទី២០ នៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ភូមិភាគអាស៊ី អាគ្នេយ៍ និងវេទិកាយុវជនលើកទី២




បន្ទាប់ពីដំណើរការកិច្ចប្រជុំអស់រយៈពេលពីរថ្ងៃ ទទួលបានលទ្ធផលផ្លែផ្កា ដោយថ្នាក់ដឹកនាំនៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហមទាំង១១ ភូមិភាគអាស៊ីអាគ្នេយ៍ បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ រាជធានីភ្នំពេញ រួចមក។

នៅល្ងាចថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ **សម្តេចកត្តព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាប្រធាន នៃកិច្ចប្រជុំថ្នាក់ដឹកនាំលើកទី២០ នៃសមាគមជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ភូមិភាគអាស៊ី អាគ្នេយ៍ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទកិច្ចប្រជុំជាផ្លូវការនៅសណ្ឋាគារសុខាភ្នំពេញ។

ថ្លែងក្នុងឱកាសបិទកិច្ចប្រជុំនេះ **សម្តេចកត្តព្រឹទ្ធបណ្ឌិត** ប្រធានកិច្ចប្រជុំបានសម្តែងនូវមោទនភាព ដែលកិច្ចប្រជុំថ្នាក់ដឹកនាំលើកទី២០ និងវេទិកាយុវជនលើកទី២បានប្រព្រឹត្តទៅដោយជោគជ័យក្នុងបរិយាកាសរីករាយ ឈរលើស្មារតីសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរឹងមាំ ដើម្បីបំពេញបន្ថែមលើដំណោះស្រាយថ្មី ក្នុងវិស័យមនុស្សធម៌។

ជាមួយគ្នានេះ **សម្តេចកត្តព្រឹទ្ធបណ្ឌិត** មានក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណចំពោះចំណាប់អារម្មណ៍ និងការគូសបញ្ជាក់របស់អគ្គលេខាធិការអាស៊ាន សហព័ន្ធអន្តរជាតិ អាយ.ស៊ី.អរ.ស៊ី ដែលបានថ្លែងបន្តការគាំទ្រ និងពង្រឹងកិច្ចសហប្រតិបត្តិការ រួមទាំងពង្រឹងយន្តការដោះ-ស្រាយរួមនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍នេះ ដែលមានគោលដៅចម្បង កសាងសមត្ថភាពសហគមន៍ឱ្យមានភាពធន់ទៅនឹងគ្រោះមហន្តរាយ។

**សម្តេចកត្តព្រឹទ្ធបណ្ឌិត** បានគូសបញ្ជាក់ថា ៖ «*សេចក្តីថ្លែងការណ៍ ដែលយើងទើបតែបានចុះហត្ថលេខារួមគ្នា គឺជាសក្ខីកម្មនៃការទទួលយកនូវបណ្តាការងារ ដែលមានដំណោះស្រាយថ្មី ក្នុងការខិតខំប្រឹងប្រែងរួមគ្នាឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងឡាយ ដើម្បីទទួលបាននូវផលវិជ្ជមានកាន់តែធំជាងមុន និងការត្រៀមលក្ខណៈរួចជាស្រេចក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ដែលបច្ចុប្បន្ននេះកើតមានកាន់តែញឹកញយជាងមុន និងមានភាពធ្ងន់ធ្ងរ*





*ខ្លាំងជាងមុន និងរួមគ្នាកសាងសហគមន៍ និងសង្គមឱ្យមានភាពធន់ និងប្រកបដោយបរិយាបន្ន។»*

ជាមួយគ្នានេះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ថ្លែងដោយក្តីមោទនភាពណាស់ ជាមួយនឹងការដាក់បញ្ចូល សេចក្តីថ្លែងការណ៍វេទិកាយុវជន ឱ្យទៅជាផ្នែកមួយដ៏សំខាន់ នៃសេចក្តីថ្លែងការណ៍រាជធានីភ្នំពេញ ដែលនេះគឺជាការគូសបញ្ជាក់នូវការពង្រឹងតួនាទីស្នូលរបស់យុវជន ការបណ្តុះថ្នាលឱ្យដីថល សម្រាប់យុវជនចូលរួមលើកស្ទួយការចែករំលែកចំណេះដឹង, ការផ្លាស់ប្តូរ បទពិសោធន៍ និងគំនិតផ្តួចផ្តើមច្នៃប្រឌិតថ្មីៗ និងជាការកសាង និងពង្រឹងសមត្ថភាពយុវជនក្នុងការដឹកនាំ ពង្រីកចំណេះដឹង និងការយល់ដឹងថ្មីៗបន្ថែមទៀត ពាក់ព័ន្ធទៅនឹងបញ្ហាប្រឈមថ្មីជាសកលដូចជា ការប្រែប្រួលអាកាសធាតុ បរិស្ថាន បច្ចេកវិទ្យា និងសុខភាពសាធារណៈជាដើម។

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បានថ្លែងអំណរគុណចំពោះកិច្ចប្រជុំដែលបានគូសបញ្ជាក់ពីសារសំខាន់ និងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការប្រែប្រួលអាកាសធាតុ និងអព្យាក្រឹត្យកាបូន តាមរយៈផែនការអភិវឌ្ឍបៃតង ដើម្បីខ្យល់បរិសុទ្ធ និងសុខុមាលភាព និងជីវភាពកាន់តែល្អប្រសើរឡើងសម្រាប់មនុស្សជាតិ ការលើកកម្ពស់ការជួបការពិគ្រោះយោបល់ដោយផ្ទាល់ និងតាមអនឡាញ ដើម្បីពង្រឹងបានថែមទៀតនូវកម្លាំងសាមគ្គីភាពរឹងមាំ កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងភាពជាដៃគូនៅក្នុងចលនា និងនៅក្រៅចលនា ជាពិសេសជាមួយនឹងអគ្គលេខាធិការដ្ឋានអាស៊ាន យន្តការនានារបស់អាស៊ាន របស់រដ្ឋាភិបាល វិស័យឯកជន រួមទាំងប្រជាពលរដ្ឋក្នុងសហគមន៍។

បន្ថែមពីនេះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បានថ្លែងថា ៖ «វត្តមានរបស់ ឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការសាខា និងក្រុមប្រតិបត្តិ មកពី ២៥រាជធានី-ខេត្ត ក្នុងកិច្ចប្រជុំនេះ នឹងបន្តចូលរួមចំណែកក្នុងការខិតខំប្រឹងប្រែងរួមរបស់កាកបាទក្រហមកម្ពុជា ក្នុងការកសាងសហគមន៍ឱ្យមានភាពធន់រឹងមាំ ទៅនឹងគ្រោះមហន្តរាយធម្មជាតិ និងមានសមត្ថភាពក្នុងការលើកកម្ពស់សុខភាពសាធារណៈ»។

ក្នុងឱកាសនេះដែរ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បានចូលរួមអបអរសាទរ កាកបាទក្រហមឥណ្ឌូណេស៊ី ដែលនឹងត្រូវធ្វើជាប្រធានបន្តវេនកិច្ចប្រជុំលើកទី២១ និងវេទិកាយុវជនលើកទី៣ នៃសមាគមជាតិកាកបាទក្រហម អឌ្ឍចន្ទក្រហមភូមិភាគអាស៊ីអាគ្នេយ៍ នៅឆ្នាំ២០២៤ ហើយក៏សូមអបអរសាទរ និងជូនពរ សមាគមជាតិកាកបាទក្រហមវៀតណាមក្នុងការទទួលធ្វើជាម្ចាស់ផ្ទះនៃសន្និសីទអាស៊ីប៉ាស៊ីហ្វិកលើកទី១១ ពីថ្ងៃ ២១ ដល់ ២៤ ខែវិច្ឆិកា ឆ្នាំ ២០២៣ ខាងមុខនេះ ក្រោមប្រធានបទ «ការត្រៀមខ្លួនរួចជាស្រេចមុនពេលមានគ្រោះមហន្តរាយនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក» ឱ្យទទួលបានជោគជ័យ។

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តមបណ្ឌិត កៅ គឹមហួន អគ្គលេខាធិការអាស៊ាន និងសហការី ដែលបានចំណាយពេលវេលាក្នុងភារកិច្ចដ៏មមាញឹក មកចូលរួមផ្តល់គុណតម្លៃបន្ថែមទៀតទៅលើកិច្ចខិតខំរបស់ចលនានៅក្នុងភូមិភាគយើងនេះ និងសូមថ្លែងអំណរគុណចំពោះ សហព័ន្ធអន្តរជាតិ អាយ.ស៊ី.អរ.ស៊ី, ថ្នាក់ដឹកនាំ និងយុវជនមកពីសមាគមជាតិទាំង ១១ ដែលបានអញ្ជើញចូលរួមប្រកបដោយការប្តេជ្ញាចិត្តឆន្ទៈមោះមុត រួមគ្នាក្នុងការស្វែងរកដំណោះស្រាយថ្មីក្នុងការងារមនុស្សធម៌ ពង្រឹងបានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ កសាង និងពង្រឹងបាននូវបណ្តាញកម្លាំងមនុស្សធម៌ ដ៏រឹងមាំមួយ នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍។

កិច្ចប្រជុំបានបញ្ចប់ដោយទទួលបានផ្លែផ្កាគួរជាទីមោទនៈ និងប្រកបដោយស្មារតីមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរឹងមាំ៕

# សូមអបអរសាទរ



## លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត

## អគ្គស្នងការសមាគមកាយឫទ្ធិនារីកម្ពុជា

ក្នុងឱកាសទទួលបានពានកិត្តិយសថ្នាក់មាស របស់មិត្តកាយឫទ្ធិនារី
តំបន់អាស៊ីប៉ាស៊ីហ្វិក និងប្រកាសនីយបត្រថ្នាក់សកលរបស់ OB-PS

# វេទិកាស្ត្រីចិន-អាស៊ាន ឆ្នាំ២០២៣ នៅទីក្រុងលីចូវ (Liuzhou) ខេត្តក្វាងស៊ី សាធារណៈរដ្ឋប្រជាមានិតចិន




កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមនៅក្នុងវេទិកាស្ត្រីចិន-អាស៊ាន ឆ្នាំ២០២៣ (2023 China-ASEAN Women's Forum) ដែលបានរៀបចំនៅទីក្រុងលីចូវ (Liuzhou) ខេត្តក្វាងស៊ី សាធារណៈរដ្ឋប្រជាមានិតចិន ។

វេទិកាចិន-អាស៊ាននេះ បានរៀបចំឡើងផ្តោតលើម្ចូលបទ **«នវានុវត្តនៅក្នុងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអភិវឌ្ឍស្ត្រី - Innovation in Science and Technology for Women's Development»** ដោយមានអ្នកចូលរួមជាថ្នាក់ដឹកនាំស្ត្រី មកពីបណ្តាប្រទេសអាស៊ាន និងសាធារណៈរដ្ឋប្រជាមានិតចិន ព្រមទាំងអ្នកឯកទេសផ្នែកបច្ចេកវិទ្យា និងអ្នកវិទ្យាសាស្ត្រជាស្ត្រីនៅក្នុងតំបន់មកជជែកពិភាក្សា និងលើកគំនិតផ្តួចផ្តើមរួមគ្នា ដើម្បីពង្រីកកាលានុវត្តភាព និងសក្តានុពលនៃការធ្វើនវានុវត្តនៅក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ការអភិវឌ្ឍស្ត្រី នៅក្នុងតំបន់អាស៊ាន និងចិន (Initiative of the ASEAN-China Women's Forum 2023) ។

នៅក្នុងឱកាសនេះ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី បានលើកឡើងអំពីគុណតម្លៃ នៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្ត (#STI) ក្នុងការឆ្លើយតបនឹងបញ្ហាប្រឈមជាសកល និងពន្លឿនការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (#SDG) ។ នៅក្នុងនោះ STI អាចពន្លឿនការអភិវឌ្ឍស្ត្រី និងការសម្រេចសមភាពយេនឌ័រ តាមរយៈច្រើនរូបភាព និងមធ្យោបាយ រួមទាំងការពង្រីកសក្តានុពលនៃការធ្វើនវានុវត្ត និងសក្តានុពលរបស់ស្ត្រី ។ លោកជំទាវបានចែករំលែកអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តឆ្នាំ២០២០-២០៣០ និងផែនទីចង្អុលផ្លូវរបស់រាជរដ្ឋាភិបាលដែលបានកំណត់ឱ្យមានស្ត្រី ៤០% នៅក្នុងចំណោមនិស្សិតសាកលវិទ្យាល័យ បញ្ចប់ការសិក្សាក្នុងជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (#STEM) នៅឆ្នាំ២០៣០ និងការផ្តោតលើការលើកកម្ពស់តួនាទីស្ត្រីក្នុងវិស័យឌីជីថល នៅក្នុងគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល ក៏ដូចជាគោលនយោបាយរដ្ឋាភិបាលឌីជីថល ក្នុងការឆ្លើយតប នឹងគម្លាតយេនឌ័រ ក្នុងវិស័យឌីជីថលនៅកម្ពុជា។

នៅក្នុងដំណើរបេសកកម្មនេះ គណៈប្រតិភូក្រសួងកិច្ចការនារី ក៏គ្រោងនឹងចូលរួមកម្មវិធីពិពរណ៌ អាស៊ាន-ចិន លើកទី២០ (20th China-ASEAN Expo) នៅទីក្រុងណាននីង ខេត្តក្វាងស៊ី ផងដែរ៕

# វេទិកាលើកទី៣ ស្តីពីការអភិវឌ្ឍស្ត្រី និងកិច្ចសហប្រតិបត្តិការអាស៊ី-អាហ្វ្រិក

"3rd Asian-African Women's Development and Cooperation Forum"

## ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ នៅទីក្រុងហុងកុង សាធារណរដ្ឋប្រជាមានិតចិន












លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី បានដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមវេទិកាលើកទី៣ ស្តីពី**ការអភិវឌ្ឍស្ត្រី និងកិច្ចសហប្រតិបត្តិការអាស៊ី-អាហ្វ្រិក "3rd Asian-African Women's Development and Cooperation Forum"** កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ នៅទីក្រុងហុងកុង សាធារណៈរដ្ឋ ប្រជាមានិតចិន។

នៅក្នុងវេទិកានោះ លោកជំទាវកិត្តិបណ្ឌិតទទួលបានការអញ្ជើញឱ្យចែករំលែកអំពីកិច្ចខិតខំប្រឹងរបស់រាជរដ្ឋាភិបាល និងមេរៀនបទពិសោធន៍របស់កម្ពុជា នៅក្នុងការលើកកម្ពស់ស្ត្រី ក្នុងកិច្ចអភិវឌ្ឍន៍ និងវិធានគាំទ្រសិទ្ធិស្ត្រី ក្រោមស្មារតីនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ។ នៅក្នុងឱកាសនោះលោកជំទាវកិត្តិបណ្ឌិត ក៏បានលើកឡើងអំពីអភិក្រមឆ្ពោះទៅមុខរបស់កម្ពុជា ក្នុងការធ្វើបរិវត្តកម្មយេនឌ័រតាមរយៈការធ្វើស្ថាប័នូបនីកម្ម ការរៀបចំថវិកាឆ្លើយតបយេនឌ័រ និងការពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃលើការងារយេនឌ័រជាដើម ។ វិស័យអាទិភាព រួមមាន៖

១.ការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងសេដ្ឋកិច្ចឌីជីថល សេដ្ឋកិច្ចដែលគិតគូរសុខុមាលភាព និងសេដ្ឋកិច្ចបៃតង។

២.ពន្លឿនបរិយាបន្នអភិបាលកិច្ច និងភាពជាអ្នកដឹកនាំ។

៣. ការបន្តលើកកម្ពស់តម្លៃស្ត្រី និងទប់ស្កាត់អំពើហិង្សាលើស្ត្រី។

៤. ចូលរួមក្នុងការអភិវឌ្ឍកម្មវិធីគាំពារសង្គមដែលឆ្លើយតបនឹងយេនឌ័រ និងការសម្រេចការគ្របដណ្តប់សុខភាពសកល។

៥. លើកកម្ពស់ការផ្លាស់ប្តូរគ្នាទៅវិញទៅមក រវាងប្រជាជនជាមួយប្រជាជាតិផ្សេងទៀត (People to People Exchanges) ព្រមទាំងភាពជាដៃគូ និងកិច្ចសហការក្នុងតំបន់ និងអន្តរជាតិ លើការលើកកម្ពស់សមភាពយេនឌ័រ។



សូមជំរាបថា ក្នុងដំណើរបេសកកម្មនោះ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ លោកជំទាវកិត្តិបណ្ឌិត ក៏បានអញ្ជើញចូលរួមដំណើរទស្សនកិច្ច នៅក្នុងវិមានសភា របស់ទីក្រុងហុងកុងផងដែរ ។

# កិច្ចសន្ទនាគោលនយោបាយអាស៊ាន-សហភាពអឺរ៉ុប ស្តីពីសិទ្ធិមនុស្ស លើកទី៥ នាដើមខែតុលា ឆ្នាំ២០២៣ នៅទីក្រុងប្រុសសែល





លោកជំទាវ **ហ៊ូ និរមិត្តា** រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី តំណាងគណៈកម្មាធិការអាស៊ានដើម្បីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ (ACWC) បានអញ្ជើញចូលរួមសកម្មភាព ស្តីអំពី កិច្ចសន្ទនាគោលនយោបាយអាស៊ាន-សហភាពអឺរ៉ុប ស្តីពី សិទ្ធិមនុស្សលើកទី៥ នាដើមខែតុលា ឆ្នាំ២០២៣ នៅទីក្រុងប្រុសសែល ប្រទេសប៊ែលហ្សិក និងទីក្រុងស្ត្រាសប៊ួក ប្រទេសបារាំង។

កិច្ចសន្ទនានេះមានគោលបំណងស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍រវាងបណ្តាប្រទេសអឺរ៉ុប និងអាស៊ាន ដើម្បីលើកកម្ពស់ការងារសិទ្ធិមនុស្សឱ្យកាន់តែល្អប្រសើរនាពេលអនាគត៕



# សិក្ខាសាលាថ្នាក់តំបន់ ស្តីពី "Online Validation Workshop of the Localisation Toolkit and Guidelines for the ASEAN Reginal Plan of Action on Women, Peace and Security (ASEAN RPA WPS)" តាមប្រព័ន្ធវីដេអូ អនឡាញ







លោកជំទាវ **គង់ សូរីតា** រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី និងជាប្រធាននៃក្រុមប្រឹក្សាអាស៊ានស្តីពី **ស្ត្រី សន្តិភាព និងសន្តិសុខ** (ASEAN Advisory Group on Women, Peace and Security) បានដឹកនាំសិក្ខាសាលាថ្នាក់តំបន់ ស្តីពី "**Online Validation Workshop of the Localisation Toolkit and Guidelines for the ASEAN Reginal Plan of Action on Women, Peace and Security (ASEAN RPA WPS)**" តាមប្រព័ន្ធវីដេអូ អនឡាញ កាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣។ កិច្ចប្រជុំនេះមានគោលបំណងដើម្បីពិភាក្សា ផ្តល់យោបល់ និងកំណត់សុពលភាពលើខ្លឹមសារសំខាន់ៗ នៃសេចក្តីព្រាងកញ្ចប់ឧបករណ៍អនុវត្ត និងគោលការណ៍ណែនាំ និងពង្រឹងមធ្យោបាយអនុវត្តផែនការសកម្មភាពថ្នាក់តំបន់ស្តីពី ស្ត្រី សន្តិភាព និង សន្តិសុខ (Reginal Plan of Action on Women, Peace and Security) ទាំងថ្នាក់ជាតិ និងមូលដ្ឋាន៕

# សិក្ខាសាលាស្តីពី «ការពង្រឹងភាពធន់ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងអាស៊ាន តាមរយៈការអភិវឌ្ឍផែនការសកម្មភាពលើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅក្នុងវិស័យនយោបាយ» នៅទីក្រុងហ្សាកាតា








នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ លោកជំទាវ **គង់ សូរីតា** រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី បានដឹកនាំក្រុមការងារអញ្ជើញចូលរួមសិក្ខាសាលា ស្តីពី«**ការពង្រឹងភាពធន់ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងអាស៊ាន តាមរយៈការអភិវឌ្ឍផែនការសកម្មភាពលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ**» នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ក្នុងគោលបំណងដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយ សម្រាប់ពង្រឹងភាពធន់ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីក្នុងអាស៊ាន ប្រមូលចងក្រងឯកសារពីលទ្ធផល នៃកិច្ចប្រជុំកំរិតតំបន់ ស្តីពីការជំរុញភាពជាអ្នកដឹកនាំ និងការចូលរួមនយោបាយរបស់ស្ត្រីនៅក្នុងអាស៊ាន រួមទាំងជំរុញការយកចិត្តទុកដាក់លើកកម្ពស់យេនឌ័រក្នុងវិស័យ STEAM នៅក្នុងគោល-នយោបាយបទដ្ឋាននានារបស់រដ្ឋសភា នៃបណ្តាប្រទេសក្នុងតំបន់អាស៊ាន សមាសភាពចូលរួមជាសមាជិកសមាជិកា នៃរដ្ឋសភា មកពីបណ្តាប្រទេសជាសមាជិកអាស៊ាន អ្នកជំនាញការ AIPA តំណាងលេខាធិការដ្ឋានអាស៊ានផ្នែកយេនឌ័រ និងកាត់បន្ថយភាពក្រីក្រ (Poverty Eradication and Gender Division) ប្រធានគណៈកម្មាធិការស្ត្រីអាស៊ាន និងដៃគូពាក់ព័ន្ធរួមមាន WFD, CFLI, UN Women, USAID សរុបចំនួន ៨៥រូប (ស្ត្រី ៣៣រូប)។

នៅក្នុងសិក្ខាសាលានេះ លោកជំទាវ **គង់ សូរីតា** បានចូលរួមធ្វើបទកិច្ចអន្តាគមន៍ស្តីអំពីបច្ចុប្បន្នភាពការសិក្សាស្រាវជ្រាវ ស្តីពីការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ និងភាពជាអ្នកដឹកនាំនៅក្នុងតំបន់អាស៊ាន ដែលប្រទេសកម្ពុជា ជាអ្នកដឹកនាំរៀបចំ រួមទាំងស្ថានភាព នៃការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយក្នុងប្រទេសកម្ពុជា៕

# ទិវាបុណ្យជាតិសាធារណរដ្ឋសិង្ហបុរីលើកទី៥៨ (58th National Day of Singapore)




លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវ** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានអញ្ជើញចូលរួមជាតំណាងរាជរដ្ឋាភិបាលកម្ពុជា ក្នុងពិធីអបអរសាទរខួបលើកទី៥៨ នៃទិវាបុណ្យជាតិសាធារណរដ្ឋសិង្ហបុរី នៅសណ្ឋាគារ Sofitel Phnom Penh Phookethra កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣។

លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី បានសម្តែងនូវការអបអរសាទរចំពោះរដ្ឋាភិបាលសឹង្ហបុរីលើការអភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យយ៉ាងឆាប់រហ័ស និងក្លាយជាខ្លាសេដ្ឋកិច្ចនៅអាស៊ី (Asian Tiger Economy) ដែលមានការសាទរជាខ្លាំង



ពីបណ្តាប្រទេសនៅក្នុងតំបន់ និងអន្តរជាតិ ។

លោកជំទាវកិត្តិបណ្ឌិតបានលើកឡើងថា សាធាណៈរដ្ឋសិង្ហបុរី គឺជាប្រទេសដែលមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយប្រទេសកម្ពុជាទៅលើការការពារសន្តិសុខនយោបាយ កិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច ទំនាក់ទំនងរវាងប្រជាជន និងប្រជាជន ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជាតាមរយៈការបណ្តុះបណ្តាលបច្ចេកទេស និងជំនាញវិជ្ជាជីវៈដល់ជនក្រីក្រ និងងាយរងគ្រោះដើម្បីរួមចំណែកដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ។

បន្ថែមពីលើនេះទៅទៀត ក្នុងនាមរដ្ឋមន្ត្រីក្រសួងកិច្ចការនារី លោកជំទាវបានសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលសិង្ហបុរី ដែលបានផ្តល់ឱកាស និងយកចិត្តទុកដាក់មើលថែដល់ស្ត្រីកម្ពុជា ដែលកំពុងរស់នៅប្រទេសសឹង្ហបុរី ដើម្បីធ្វើការ និងផ្គត់ផ្គង់គ្រួសាររបស់ពួកគេនៅឯស្រុកកំណើត ជាពិសេសក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩ ។

មុននឹងបញ្ចប់ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី បានថ្លែងអំណរគុណដល់រដ្ឋាភិបាលសិង្ហបុរី ដែលបានបញ្ជូនអត្តពលិករបស់ខ្លួនទៅចូលរួមប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅកម្ពុជាក្នុងខែឧសភា និងមិថុនា ក៏ដូចជាមានការកោតសរសើរចំពោះការសម្តែងដ៏អស្ចារ្យរបស់ពួកគេក្នុងការនាំយកមេដាយ ជាច្រើនមកជូនប្រទេស៕

# ពិធីសម្តែងការគួរសម និងជម្រាបលា របស់អគ្គរដ្ឋទូតវិសាមញ្ញ ពេញសមត្ថភាព នៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា








លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានអនុញ្ញាតឱ្យលោកជំទាវ **ម៉ារីយ៉ា ដែល ខាមេនម៉ូរេណូ** (Maria Del Carmen Moreno) ឯកអគ្គ-រដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលចប់អណត្តិបេសកកម្មការទូត ដើម្បីសម្តែងការគួរសម និងជម្រាបលា កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងកិច្ចការនារី។

ក្នុងជំនួបនេះ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះការអញ្ជើញរបស់លោកជំទាវឯកអគ្គ-រដ្ឋទូត និងអបអរសាទរនូវភាពជោគជ័យរបស់លោកជំទាវ ក្នុងការបំពេញបេសកកម្មជាឯកអគ្គរដ្ឋទូតប្រចាំព្រះរាជា-ណាចក្រកម្ពុជា ។ លោកជំទាវកិត្តិបណ្ឌិត សម្តែងនូវការកោតសរសើរចំពោះការទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងព្រះរាជា-ណាចក្រកម្ពុជា និងសហភាពអឺរ៉ុបទៅលើជំនួយគាំទ្រលើកិច្ចអភិវឌ្ឍន៍ទាំងផ្នែកសេដ្ឋកិច្ច និងសង្គម ជាពិសេស ការជួយគាំទ្រ និងសម្របសម្រួលសម្រាប់កិច្ចប្រជុំ ASEM Forum on Women, Peace and Security នៅឆ្នាំ២០២១ ។

ក្នុងឱកាសនេះ លោកជំទាវឯកអគ្គរដ្ឋទូត បានសម្តែងនូវការអបអរសាទរដល់លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី ដែលព្រះមហាក្សត្រ បានត្រាស់បង្គាប់តែងតាំង លោកជំទាវកិត្តិ-បណ្ឌិត ជារដ្ឋមន្ត្រីក្រសួងកិច្ចការនារី សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា និងបានកោតសរសើរលើការដឹកនាំដ៏ឈ្លាសវៃរបស់លោកជំទាវកិត្តិបណ្ឌិតក្នុងការដឹកនាំក្រសួងកិច្ចការ-នារីកន្លងមកនៅលើបេសកកម្មលើកកម្ពស់ និងបង្កើនភាពអង់អាចដល់ស្ត្រីនៅកម្ពុជា ៕

# លោកជំទាវកិត្តិបណ្ឌិត រដ្ឋមន្ត្រីក្រសួងកិច្ចការនារី អនុញ្ញាតឱ្យលេខាទី១ស្ដីទី នៃស្ថានទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា ចូលជួបសំដែងការគួរសម



នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ នៅទីស្ដីការក្រសួងកិច្ចការនារី លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានទទួលជួប **Mr.Connor Floyd** លេខាទី១ស្ដីទី នៃស្ថានទូតអូស្ត្រាលី ប្រចាំប្រទេសកម្ពុជា និងលោកបណ្ឌិត **រស់ ឆាយ** មន្ត្រី នៃស្ថានទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា ក្នុងគោលបំណង បង្ហាញជូននូវវឌ្ឍនភាពនៃកម្មវិធីសហប្រតិបត្តិការ អូស្ត្រាលី-កម្ពុជា ដើម្បីការផ្ដល់សេវាប្រកបដោយនិរន្តភាព និងសមធម៌ ដំណាក់កាលទី១ ACCESS I ឆ្នាំ(២០១៨- ២០២៣) និងបង្ហាញអំពីសេចក្ដីសង្ខេបកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្ដល់សេវាប្រកបដោយ និរន្តភាព និងសមធម៌ ដំណាក់កាលទី២ ACCESS II ឆ្នាំ(២០២៣-២០២៨) ដើម្បីស្នើបន្តកិច្ចសហការជាមួយក្រសួងកិច្ចការនារី រយៈពេល ៥ឆ្នាំទៅមុខទៀត។



ក្នុងជំនួបនេះ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីបានស្វាគមន៍យ៉ាងរីករាយចំពោះការអញ្ជើញរបស់លោកលេខាទី១ ស្ដីទី នៃស្ថានទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា និង អបអរសាទរ នូវវឌ្ឍនភាពដែលកម្មវិធីACCESS សម្រេចបានរយៈពេល ៥ឆ្នាំកន្លងមក ក្នុងការជួយគាំទ្រក្នុងការអនុវត្តការងារដើម្បី ទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។

លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី បានថ្លែងអំណរគុណដល់ប្រទេសអូស្ត្រាលី និងសូមកោតសរសើរចំពោះកិច្ចខិតខំរបស់ក្រុមការងារក្រសួងកិច្ចការនារី និងរីករាយបន្តកិច្ចសហការជាមួយកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជា ដើម្បីការផ្ដល់សេវាប្រកបដោយនិរន្តភាព និងសមធម៌ដំណាក់កាលទី២ (ACCESS) តទៅទៀត៕

# ពិធីបើកយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីជម្ងឺមហារីកសុដន់ AIA Fit for Hope 2023 នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា





នាព្រឹកថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ អមដោយគណៈអធិបតី ឯកឧត្តម **សែម ផល្លា** អគ្គលេខាធិការនៃគណៈកម្មាធិការប្រតិបត្តិម៉ារ៉ាតុង និងលោក Andrew Loh អគ្គនាយកក្រុមហ៊ុន អេ អាយ អេ ខេមបូឌា ឡាយហ្វ៍អ៊ីនសួរេន មកក្នុងពិធីបើកយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីជម្ងឺមហារីកសុដន់ AIA Fit for Hope 2023 នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា ដែលមានអ្នកចូលរួមសរុបចំនួន ៥៥នាក់ (ស្ត្រី ២៥នាក់)។

លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានមានប្រសាសន៍ថា កម្មវិធីយុទ្ធនាការ Fit for Hope នេះ រៀបចំឡើងតាំងពីឆ្នាំ២០១៧ និងបានឆ្លើយតបទៅនឹងចក្ខុវិស័យ នៃកិច្ចសហការរវាងក្រសួងកិច្ចការនារី និងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត អេ អាយ អេ ខេមបូឌា លើគម្រោង "**លើកកម្ពស់សុខភាព និងហិរញ្ញវត្ថុសម្រាប់ស្ត្រីកម្ពុជា**" ដែលមានរយៈពេល ៥ឆ្នាំ ក្នុងគោលបំណងបង្កើនការយល់ដឹងដល់ស្ត្រី និងគ្រួសារ អំពីសិទ្ធិទាក់ទងនឹងសុខភាព ជម្ងឺមិនឆ្លង រួមមានជម្ងឺមហារីកមាត់ស្បូន ជម្ងឺមហារីកសុដន់ មូលដ្ឋានគ្រឹះនៃអាហារូបត្ថម្ភ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុក្នុងចំណោមប្រជាជនកម្ពុជា ដែលរស់នៅក្នុងខេត្តគោលដៅចំនួន ៤ខេត្ត គឺខេត្តកំពត ខេត្តកំពង់ចាម ខេត្តសៀមរាប និងខេត្តបាត់ដំបង និងជួយជម្រុញលើកទឹកចិត្តស្ត្រីឱ្យមកទទួលបានការពិនិត្យរោគវិនិច្ឆ័យជម្ងឺនេះ ដើម្បីស្វែងយល់លម្អិតអំពីជម្ងឺនេះ ក៏ដូចជារបៀបពិនិត្យរោគវិនិច្ឆ័យឱ្យបានទាន់ពេលវេលា ដើម្បីផ្តល់ភាពងាយស្រួលក្នុងការព្យាបាល និងទទួលបានឱកាសខ្ពស់ក្នុងការជាសះស្បើយ និងសង្គ្រោះជីវិតផងដែរ។

លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីបានមានប្រសាសន៍ផងដែរថា បច្ចុប្បន្ននេះនៅប្រទេសកម្ពុជា ដោយសារខ្វះការយល់ដឹង ៧០% នៃអ្នកជម្ងឺមហារីកសុដន់ មកទទួលការព្យាបាលនៅដំណាក់កាលចុងក្រោយនៃជម្ងឺ។ ប្រសិនបើគាត់ឆាប់រកវិនិច្ឆ័យបានលឿន នោះឱកាសនៃការព្យាបាលជាមានប្រសិទ្ធភាពខ្ពស់ ដូចនេះហើយ ខ្ញុំសូមកោតសរសើរ និងគាំទ្រដល់ក្រុមហ៊ុន អេ អាយ អេ ខេមបូឌា មន្ទីរពេទ្យដៃគូ និងដៃគូពាក់ព័ន្ធទាំងអស់ បានផ្តួចផ្តើមក្នុងការបង្កើតយុទ្ធនាការ ប្រចាំឆ្នាំ Fit for Hope ដើម្បីជួយសង្គ្រោះជីវិតស្ត្រីកម្ពុជារាប់ពាន់នាក់ពីជម្ងឺមហារីកសុដន់។

ខ្ញុំសូមអំពាវនាវដល់សាធារណជន ជាពិសេសស្ត្រី សូមអញ្ជើញទៅពិនិត្យ ស្វែងរកជំងឺមហារីកសុដន់នៅតាមទីតាំង និងកាលបរិច្ឆេទដែលបានកំណត់ក្នុងយុទ្ធនាការ Fit for Hope 2023 ដូចជានៅ AEON សែនសុខ and Factory Phnom Penh and at selected AIA Cambodia partner hospitals in numerous provinces and cities៕

# ពិធីជួបពិភាក្សាការងារ ជាមួយឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា

**លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងឯកឧត្តមឯកអគ្គរាជទូតជប៉ុន ឯកភាពគ្នាឱ្យបង្កើតក្រុមការងារបច្ចេកទេស ដើម្បីសិក្សាបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រី នៅកម្ពុជា**




លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣ បានជួបពិភាក្សាការងារជាមួយឯកឧត្តម **UENO Atsushi** ឯកអគ្គ-រាជទូតជប៉ុនប្រចាំកម្ពុជា នៅទីស្តីការក្រសួង។ នៅក្នុងកិច្ចពិភាក្សានេះ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរាជទូត បានពិភាក្សាគ្នាលើការគាំទ្រការអភិវឌ្ឍន៍សហគ្រិនស្ត្រី ជាពិសេសស្ត្រីធ្វើអាជីវកម្ម នៅក្នុងកម្រិតមីក្រូ និងតូច ដើម្បីឈានទៅជួយគាំទ្រលើការបង្កើត និងដំណើរការមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនស្ត្រី។ ជំនួបនេះបានទទួលលទ្ធផលជាផ្លែផ្កា ដោយភាគីទាំងពីរបានអនុញ្ញាតឱ្យបង្កើតជាក្រុមការងារបច្ចេកទេស ដើម្បីសិក្សារៀបចំជាគម្រោងសម្រាប់ឱ្យមានការគាំទ្រពីជប៉ុន ដោយសិក្សាមើលថា តើភាគីជប៉ុនអាចមានផ្នែកណាមួយ ដែលអាចជួយគាំទ្រ។ លោកជំទាវកិត្តិបណ្ឌិតមានប្រសាសន៍ថា នេះជាគម្រោងថ្មីមួយរបស់ក្រសួងកិច្ចការនារី ហើយជាតម្រូវការចាំបាច់របស់សង្គម ខណៈបច្ចុប្បន្នស្ត្រីដែលជាម្ចាស់អាជីវកម្មកម្រិតតូច និងមីក្រូ មានចំនួន ៦១% ដោយភាគច្រើនជាអ្នកលក់ដូរនៅតាមផ្សារ និងតាមផ្លូវផ្សេងៗ ដែលនេះជាចំណុចមួយត្រូវការការគាំទ្រពីរាជរដ្ឋាភិបាល។ តាមគម្រោងមជ្ឈមណ្ឌលនេះ មានមុខងារ ៤សំខាន់៖**ទី១.** ជួយស្ត្រីដែលមានបំណងចង់បង្កើតអាជីវកម្មដំបូង ឱ្យមានកន្លែងសម្រាប់ពួកគាត់បើកអាជីវកម្ម។ **ទី២.**អ្នកដែលរកស៊ីនៅតាមផ្លូវ ឬតាមផ្សារ មជ្ឈមណ្ឌលជួយបង្រៀនពួកគាត់អំពីវិធីគ្រប់គ្រងហិរញ្ញវត្ថុ និងការអភិវឌ្ឍគំនិតច្នៃប្រឌិត ដើម្បីឱ្យមានចំណូលច្រើនជាងមុន។ **ទី៣.**ជួយបង្កើនសេដ្ឋកិច្ចដល់ពួកគាត់ និង**ទី៤.** ជាទីកន្លែងមួយ សម្រាប់ការតាំងពិព័រណ៌ផលិតផល ឬសេវាកម្ម សម្រាប់ស្ត្រី។

គម្រោងនៃការបង្កើតមជ្ឈមណ្ឌលនេះ គ្រោងនឹងចាប់ផ្តើមដំណើរការនៅចុងឆ្នាំ២០២៤ខាងមុខ ហើយលោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី រំពឹងថា ក្រោយមជ្ឈមណ្ឌលនេះដំណើរការ នឹងមានស្ត្រីជាសហគ្រិន ចន្លោះពី ១០០ ទៅ ២០០នាក់ ក្នុងរយៈពេល១ឆ្នាំៗ បានទទួលការបណ្តុះបណ្តាលពីមជ្ឈ-មណ្ឌលនេះ។ ក្នុងជំនួបនេះដែរ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរាជទូត ក៏បានកត់សម្គាល់អំពីគុណតម្លៃ និងសមិទ្ធផលនានា ដែលបានសហការគ្នាប្រមាណ១៦ឆ្នាំកន្លងមក ដែលអង្គការ JICA និងស្ថានទូតជប៉ុនប្រចាំកម្ពុជា បានចាប់ផ្តើមធ្វើការងារពាក់ព័ន្ធនឹងបញ្ហាស្ត្រី៕

# លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី អនុញ្ញាតឱ្យបណ្ដាញសហគ្រិនស្ត្រីកម្ពុជា (CamWEN) ក្នុងនាមជាប្រធានសហគ្រិនស្ត្រីអាស៊ាន (AWEN) ចូលជួបសម្ដែងការគួរសម និងរាយការណ៍អំពីវឌ្ឍនភាពការងារ





លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានអនុញ្ញាតឱ្យបណ្ដាញសហគ្រិនស្ត្រីកម្ពុជា ចូលជួបសម្ដែងការគួរសម និងរាយការណ៍ជូនអំពីវឌ្ឍនភាពការងារកន្លងមក ព្រមទាំងទិសដៅអាទិភាពរបស់ខ្លួន នៅទីស្ដីការក្រសួងកិច្ចការនារី កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ។

នៅក្នុងឱកាសជួបសម្ដែងការគួរសមនោះ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី បានអបអរសាទរដល់ស្ត្រីសហគ្រិនកម្ពុជា ចំនួន ១៥រូប ដែលបានទទួលពានរង្វាន់ស្ត្រីសហគ្រិនឆ្នើមនៅតំបន់អាស៊ាន កាលពីដើមខែកញ្ញា ឆ្នាំ២០២៣ នេះ។

នៅឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ កម្ពុជា ក៏បានទទួលធ្វើជាម្ចាស់ផ្ទះនិងប្រធានប្ដូរវេននៃបណ្ដាញសហគ្រិនស្ត្រីអាស៊ាន (ASEAN Entrepreneur′ Network–AWEN) ដែលដឹកនាំសម្របសម្រួល ដោយបណ្ដាញសហគ្រិនស្ត្រីកម្ពុជា (CamWEN) ។





ជាការឆ្លើយតបតាមសំណូមពររបស់ប្រធាន AWEN ឆ្នាំ២០២៣ ក្រសួងកិច្ចការនារី សូមស្វាគមន៍ចំពោះកិច្ចសហការ និងបន្តគាំទ្រដល់ក្រុមការងារ និងបណ្ដាញសហគ្រិនស្ត្រីកម្ពុជា ដើម្បីដឹកនាំធ្វើជាម្ចាស់ផ្ទះ និងប្រធាន AWEN ដោយជោគជ័យ និងទទួលបានលទ្ធផលកាន់តែល្អប្រសើរសម្រាប់សហគមន៍អាស៊ានទាំងមូល ៕

# លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីអនុញ្ញាតឱ្យសមាគមសហគ្រិនស្ត្រីកម្ពុជា (CWEA) ចូលជួបសម្តែងការគួរសម និងរាយការណ៍ពីសកម្មភាពដែលសមាគមបានអនុវត្តកន្លងមក



កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣នៅទីស្តីការក្រសួងកិច្ចការនារី លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បានអនុញ្ញាតិឱ្យសមាគមសហគ្រិនស្ត្រីកម្ពុជា (CWEA) ចូលជួបសម្តែងការគួរសម និងរាយការណ៍ពីសកម្មភាពដែលសមាគមបានអនុវត្តកន្លងមក។

នៅក្នុងឱកាសនោះ លោកជំទាវឧកញ៉ា **កែវ មុំ** ប្រធានសមាគមសហគ្រិនស្ត្រីកម្ពុជា បានរាយការណ៍អំពីវឌ្ឍនភាពការងាររបស់សមាគមកន្លងមក រួមទាំងការពង្រីកសមាជិកភាព និងសាខារបស់ខ្លួននៅតាមបណ្តាខេត្ត ការរៀបចំកម្មវិធីអភិវឌ្ឍសមត្ថភាពសមាជិករបស់ខ្លួន ការស្វែងរកការគាំទ្រមតិ និងចងបណ្តាញជាមួយដៃគូពាក់ព័ន្ធ។ លោកជំទាវឧកញ៉ា **កែវ មុំ** បានថ្លែងអំណរគុណដល់លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួងកិច្ចការនារី ដែលជាអ្នកផ្តួចផ្តើមបង្កើតសមាគម និងជាបន្តបន្ទាប់តែងតែគាំទ្រ និងផ្តល់ការណែនាំតម្រង់ទិសដល់សមាគម ដែលបណ្តាលឱ្យមានការរីកចម្រើន និងការវិវត្តន៍ដូចបច្ចុប្បន្ន ។

ក្នុងកិច្ចប្រជុំនេះផងដែរ លោកជំទាវកិត្តិបណ្ឌិតក៏បានមានអនុសាសន៍លើកទឹកចិត្តចំពោះការបន្តអនុវត្តន៍ការងារដ៏ប្រសើររបស់សហគ្រិន និងផ្តល់នូវដំបូន្មានល្អៗ ដូចជាការស្វែងរកទីផ្សារហិរញ្ញវត្ថុ ព្រមទាំងការវេចខ្ចប់ផលិតផលប្រកបដោយសុវត្ថិភាពក្នុងសហគ្រាស ខ្នាត មីក្រូ តូច និងមធ្យម។

ឆ្លើយតបនឹងសំណូមពរ និងតម្រូវការនានា ដែលបានលើកឡើងដោយសមាគមនាឱកាសនេះ លោកជំទាវកិត្តិបណ្ឌិតបានលើកទឹកចិត្តឱ្យសមាគមបន្តចូលរួមផ្តល់មតិយោបល់ទាំងនោះ នៅក្នុងក្រុមការងាររដ្ឋាភិបាល និងវិស័យឯកជនទៅតាមមុខងារនីមួយៗ ហើយក្រសួងក៏កំពុងសិក្សាអំពីលទ្ធភាព ក្នុងការភ្ជាប់ទំនាក់ទំនងក្នុងការរៀបចំជំនួប និងការធ្វើការភ្ជាប់ធុរកិច្ចជាមួយសហគ្រិនស្ត្រីនៅតាមបណ្តាប្រទេសនានានៅក្នុងតំបន់អាស៊ាន ដូចអាស៊ាន-បូក ដូចជាចិន កូរ៉េ ជប៉ុន និងអូស្ត្រាលី ជាដើម ជាពិសេសនៅក្នុងអំឡុងពេលកម្ពុជាកំពុងធ្វើជាប្រធានបណ្តាញសហគ្រិនស្ត្រីអាស៊ាន (AWEN)។

ជាទីបញ្ចប់នៃកិច្ចប្រជុំ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីក៏បានបញ្ជាក់ផងដែរថា ការរីកចម្រើននូវអាជីវកម្ម ដែលគ្រប់គ្រងដោយស្ត្រី បានជះឥទ្ធិពលជាវិជ្ជមាន ដល់ការអភិវឌ្ឍន៍សង្គម និងកំណើនសេដ្ឋកិច្ចកម្ពុជា៕

# ពិធីប្រកាសបើកយុទ្ធនាការទិវាអន្តរជាតិក្មេងស្រី ឆ្នាំ២០២៣ ក្រោមប្រធានបទ «លើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ក្មេងស្រី ក្នុងយុគសម័យឌីជីថល»




ពិធីប្រកាសបើកយុទ្ធនាការទិវាអន្តរជាតិក្មេងស្រី ឆ្នាំ ២០២៣ ក្រោមប្រធានបទ «**លើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ក្មេងស្រី ក្នុងយុគសម័យឌីជីថល**» ចាប់ផ្តើមពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣នេះទៅ ក្រោមអធិបតីភាពលោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី។

នៅក្នុងពិធីបើកយុទ្ធនាការនេះ ប្រារព្ធឡើងក្នុង «**កម្មវិធីរត់ដើម្បីក្មេងស្រី និងដើម្បីទាំងអស់គ្នា**» ដែលមានអ្នកចូលរួម ៥០០នាក់ នៅមជ្ឈមណ្ឌលកោះពេជ្រ កាលពីព្រឹកថ្ងៃទី៨ ខែតុលាឆ្នាំ២០២៣នេះ។ លោកជំទាវកិត្តិបណ្ឌិតរដ្ឋមន្ត្រីក្រសួងកិច្ចការនារីបានលើកឡើងថា យុទ្ធនាការនេះ មានគោលបំណងចម្បងៗចំនួន២ គឺៈ

**ទី១**).លើកកម្ពស់ការគាំទ្រពីសំណាក់គ្រួសារ សហគមន៍ និងដៃគូពាក់ព័ន្ធ រួមទាំងបុរស និងក្មេងប្រុស ក្នុងការលើកកម្ពស់ ការទទួលបានសិទ្ធិពេញលេញរបស់ក្មេងស្រី និងការចូលរួមរបស់ក្មេងស្រី នៅក្នុងសង្គម-សេដ្ឋកិច្ច។

**ទី២**).ការបង្កើនភាពអង់អាចដល់ក្មេងស្រី ក្នុងការអនុវត្តសិទ្ធិ អភិវឌ្ឍសមត្ថភាព និងបណ្តុះសក្តានុពលក្នុងការដឹកនាំខ្លួនឯង និងចូលរួមដោយពេញលេញ នៅក្នុងការអភិវឌ្ឍគ្រួសារ សេដ្ឋកិច្ច និងសង្គមជាតិ។

យុទ្ធនាការនេះ រៀបចំឡើងក្រោមភាពជាដៃគូ រវាងក្រសួងកិច្ចការនារី និងអង្គការផ្លែនអន្តរជាតិកម្ពុជា ព្រមទាំងចូលរួមពីក្រសួង-ស្ថាប័ន អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន ប្រព័ន្ធផ្សព្វផ្សាយ និងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំព្រឹត្តិការណ៍រត់ដើម្បីក្មេងស្រី និងដើម្បីទាំងអស់គ្នា កម្មវិធីនៅតាមបណ្តាខេត្ត កម្មវិធីប្រកួតបាល់ទាត់នារី កម្មវិធីផ្សព្វផ្សាយតាមប្រព័ន្ធឌីជីថល និងប្រព័ន្ធផ្សព្វផ្សាយនានា និងកម្មវិធីក្មេងស្រីកាន់តួនាទីជំនួសជាដើម ។

# កិច្ចប្រជុំពិគ្រោះយោបល់លើឯកសារផែនទីតំរង់ទិសឆ្ពោះទៅការធ្វើវិសោធនកម្មច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារ ជនរងគ្រោះឆ្នាំ២០០៥






កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រសួងកិច្ចការនារី ដោយមានការគាំទ្រពីអង្គការ UNWomen បានរៀបចំ កិច្ចប្រជុំពិគ្រោះយោបល់ លើឯកសារផែនទីតំរង់ទិសឆ្ពោះទៅការធ្វើវិសោធនកម្មច្បាប់ ស្តីពីការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី ក្នុងគោលបំណងដើម្បីធ្វើការពិនិត្យ ពិគ្រោះយោបល់លើឯកសារទស្សនទាន និងដើម្បីប្រមូលធាតុចូលក្នុងការកំណត់ទិសដៅឈានទៅដល់ការធ្វើវិសោធនកម្មច្បាប់ ដោយមានការចូលរួមពីក្រសួងស្ថាប័ន និងអង្គការពាក់ព័ន្ធ ចំនួន៤៨នាក់ ក្នុងនោះស្ត្រី៣១នាក់ នៅសណ្ឋាគារកាំបូឌីយ៉ាណា៕

# វគ្គបណ្តុះបណ្តាលស្តីពី «ជំនាញស្វែងរកការគាំទ្រមតិលើបញ្ហាយេនឌ័រ និងពិការភាព»




ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៣ លោកជំទាវ **ញ៉ែម មរកត** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារសកម្មភាពជនពិការរបស់ក្រសួងកិច្ចការនារី បានអញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី **ជំនាញស្វែងរកការគាំទ្រមតិលើបញ្ហាយេនឌ័រ និងពិការភាព** នៅខេត្តកែប ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីបរិយាបន្នយេនឌ័រ និងពិការ-ភាព។សមាសភាពចូលរួមមាន៖ ថ្នាក់ដឹកនាំមន្ត្រីក្រសួងកិច្ចការនារី ប្រធាន/អនុប្រធានមន្ទីរ ប្រធាន/អនុប្រធានការិយាល័យ មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី នៃរាជធានី/ខេត្តចំនួន០៩ រួមមានខេត្ត កោះកុង ព្រះសីហនុ កំពង់ស្ពឺ តាកែវ កណ្តាល ព្រៃវែង សៀមរាប និងស្វាយរៀង សរុបចំនួន ៩២នាក់ (ស្ត្រី ៣៨នាក់)។ វគ្គបណ្តុះបណ្តាលនេះមានរយៈពេល០៣ថ្ងៃ ចាប់ពីថ្ងៃទី១៨ ដល់២០ ខែតុលា ឆ្នាំ២០២៣៕

# ពិធីបិទបញ្ចប់និងបូកសរុបលទ្ធផលរបស់គម្រោងសហគ្រិននារីសកម្ម និងដើម្បី អបអរសាទរសមិទ្ធផលរបស់គម្រោង



គម្រោងសហគ្រិននារីសកម្ម (WE Act Cambodia) ក្នុងរយៈពេល៥ ឆ្នាំ គិតចាប់ពីឆ្នាំ២០១៨ បានគាំទ្រដល់សហគ្រិនស្ត្រីវ័យក្មេង អាជីវករក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ បុគ្គលស្វ័យនិយោជន៍ យុវជន សហគមន៍ LGBTQI Plus ជនមានពិការភាព និងជនមានភាពងាយរងគ្រោះដ៏ទៃទៀត ប្រមាណបីម៉ឺននាក់ (៣០.០០០នាក់) ដោយផ្ទាល់លើការពង្រឹងចំណេះដឹង ចំណេះធ្វើ ជំនាញទាក់ទងនឹងការធ្វើអាជីវកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ការធ្វើទីផ្សារឌីជីថល ភាពជាអ្នកដឹកនាំ សិទ្ធិសេដ្ឋកិច្ច-សង្គម និងភ្ជាប់បណ្តាញអាជីវកម្ម ។

កាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣ ក្នុងភាពដៃគូរវាងក្រសួងកិច្ចការនារី និងអង្គការផេកកម្ពុជា បានរៀបចំ «**ពិធីបិទបញ្ចប់និងបូកសរុបលទ្ធផលរបស់គម្រោងសហគ្រិននារីសកម្ម និងដើម្បីអបអរសាទរសមិទ្ធផលរបស់គម្រោង**» ក្រោមអធិបតីភាពលោកជំទាវ **ត្រឹ ណារាលីស** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឯកឧត្តម **W. Patrick Murphy** ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា លោក **ជេមស៍ ប្រោល** នាយកប្រចាំតំបន់របស់អង្គការផេក និងលោកស្រី **Sabine Joukes** នាយិកាអង្គការផេកកម្ពុជា ព្រមទាំងមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គការសង្គម ស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ និងបងប្អូនសហគ្រិនស្ត្រី និងយុវជនដែលទទួលផលពីគម្រោងកន្លងមក។




សូមបញ្ជាក់ផងដែរថា ក្រោមក្របខណ្ឌ នៃភាពជាដៃគូជាមួយក្រសួងកិច្ចការនារី គម្រោងសហគ្រិននារីសកម្មនេះ អនុវត្តដោយអង្គការផេកកម្ពុជា ក្រោមជំនួយពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងកិច្ចសហការជាមួយសហគ្រិនស្ត្រីវ័យក្មេងក្នុងស្រុក និងស្ថាប័នគាំទ្រសហគ្រិនស្ត្រី ដូចជា៖ សមាគមសហគ្រិនគ្រឹះស្ថានសិក្សាអប់រំ ភ្នាក់ងារគាំទ្រផ្នែកច្បាប់ ស្ថាប័នហិរញ្ញវត្ថុ អង្គការក្រៅរដ្ឋាភិបាល និងអង្គការសហគមន៍មូលដ្ឋានក្នុងតំបន់គោលដៅរបស់គម្រោង នៅរាជធានីភ្នំពេញ សៀមរាប បាត់ដំបង កំពង់ចាម កំពត កែប ព្រះសីហនុ៕

# វគ្គបណ្តុះបណ្តាល ស្តីពី ការគ្រប់គ្រងរដ្ឋបាល




ថ្ងៃទី២៥ - ២៧ ខែតុលា ឆ្នាំ២០២៣ នាយកដ្ឋានរដ្ឋបាលបុគ្គលិក នៃក្រសួងកិច្ចការនារី សហការជាមួយមន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងរដ្ឋបាល ក្រោមអធិបតីភាព **លោកជំទាវ ឃឹម ចំរើន** រដ្ឋលេខាធិការទទួលបន្ទុកការងាររដ្ឋបាល ដើម្បីអភិវឌ្ឍសមត្ថភាពលើប្រព័ន្ធគ្រប់គ្រងមុខងារសាធារណៈ និងគ្រប់គ្រងធនធានមនុស្ស ដោយផ្អែកលើសមិទ្ធកម្មនវានុវត្ត និងបច្ចេកវិទ្យាឌីជីថល និងផលិតភាពការងារ ស្របតាមស្នូល នៃយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ មុំទី១ នៃការពង្រឹង និងកែទម្រង់ស្ថាប័ន ដល់មន្ត្រីទទួលបន្ទុកការគ្រប់គ្រងរដ្ឋបាល បុគ្គលិកក្រសួង និងមន្ទីរកិច្ចការនារីខេត្តកែប កំពត កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ព្រះវិហារ សៀមរាប ឧត្តរមានជ័យ និងខេត្តប៉ៃលិន ចំនួន ៥១នាក់ (ស្រី ៤១នាក់) នៅខេត្តបន្ទាយមានជ័យ៕





# «វគ្គបណ្ដុះបណ្ដាលសេរីទី២ ស្ដីពី ការបង្កើតមាតិកាឌីជីថល និង ការប្រើប្រាស់បណ្ដាញសង្គម ប្រកបដោយប្រសិទ្ធភាព»



នាយកដ្ឋានព័ត៌មាន នៃក្រសួងកិច្ចការនារីបានរៀបចំពិធីបើកវគ្គបណ្ដុះបណ្ដាលសេរីទី២ ស្ដីពី «**ការបង្កើតមាតិកាឌីជីថល និងការប្រើប្រាស់បណ្ដាញសង្គមប្រកបដោយប្រសិទ្ធភាព**» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកជំទាវ **ប៊ុន ពុទ្ធី** រដ្ឋលេខាធិការ ក្រសួងកិច្ចការី និងមានការចូលរួមពីលោកជំទាវ **ថងគៀន ឆ័យម៉ាលី** អនុរដ្ឋលេខាធិការ លោក **គង់ សុវណ្ណា** តំណាងអង្គការ Catalyst+ ទីប្រឹក្សាបច្ចេកទេស និងសិក្ខាកាមសរុបចំនួន ៥៥នាក់។

វគ្គបណ្ដុះបណ្ដាលជាសេរីទី២ រៀបចំឡើងក្នុងគោល-បំណងពង្រឹងសមត្ថភាពមន្ត្រីអន្តរនាយកដ្ឋានទទួលបន្ទុកបណ្ដាញសង្គម ក្រសួងកិច្ចការនារី និងមន្ត្រីការិយាល័យព័ត៌មាន មន្ទីរកិច្ចការនារី ២៥រាជធានី-ខេត្ត ក្នុងការបង្កើតខ្លឹមសារ និងមាតិកាឌីជីថល ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី តាមរយៈប្រព័ន្ធផ្សព្វផ្សាយបណ្ដាញសង្គម។

វគ្គបណ្ដុះបណ្ដាលនេះបានរៀបចំចំនួន ២ដង ៖ លើកទី១ នៅថ្ងៃទី២៣ ដល់ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ជូនមន្ត្រីអន្តរនាយកដ្ឋានទទួលបន្ទុកបណ្ដាញសង្គមក្រសួងកិច្ចការ-នារី ចំនួន ២០នាក់ និងលើកទី២ នៅថ្ងៃទី១ ដល់ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ជូនមន្ត្រីការិយាល័យព័ត៌មាន មន្ទីរកិច្ចការនារី ២៥រាជធានី-ខេត្ត ចំនួន ៥៥ នាក់ កាលពីថ្ងៃពុធ ៣រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣៕



# សិក្ខាសាលាស្តីពី ការឆ្លុះបញ្ចាំង នៃការអនុវត្តការងាររបស់ក្រុមការងារ ឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកន្លែងផ្តល់សេវាចម្រុះឆ្លើយតបជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ



កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ ក្រសួងកិច្ចការនារី ដោយមានការសហការពីអង្គការUNFPA បានរៀបចំសិក្ខាសាលាស្តីពីការឆ្លុះបញ្ចាំងនៃការអនុវត្តការងាររបស់ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកន្លែងផ្តល់សេវាចម្រុះឆ្លើយតបជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្រោមអធិបតីភាព លោកជំទាវ **ឡុង សុផល្លី** រដ្ឋលេខាធិការក្រសួងកិច្ចការនារី។

គោលបំណងសិក្ខាសាលា គឺដើម្បីបង្ហាញពីប្រវត្តិ នៃការរៀបចំក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកន្លែងផ្តល់សេវាចម្រុះឆ្លើយតបជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ចែករំលែកបទពិសោធន៍ដែលបានអនុវត្តការងាររបស់ក្រុមការងារ និងការបង្ហាញពីដំណើរការនៃការរៀបចំក្រុមការងារឆ្លើយតប GBV កន្លែងផ្តល់សេវាចម្រុះ និងការពង្រឹងសមត្ថភាពរបស់ក្រុមការងារ។

សិក្ខាសាលានេះ មានការអញ្ជើញចូលរួមចែករំលែកបទពិសោធន៍ពីការអនុវត្តក្រុមការងារឆ្លើយតបជាពហុវិស័យ ឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកន្លែងផ្តល់សេវាចម្រុះឆ្លើយតបជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបានកំពុងដំណើរការអនុវត្តការងារទាំង ១០ខេត្ត រួមមាន៖ ខេត្តកំពង់ចាម ត្បូងឃ្មុំ សៀមរាប ស្ទឹងត្រែង រតនគិរី ព្រះវិហារ កំពង់ស្ពឺ ព្រះសីហនុ កំពង់ធំ និងខេត្តឧត្តរមានជ័យ ជូនទៅអ្នកពាក់ព័ន្ធទាំង ២៥ រាជធានី-ខេត្ត។

សិក្ខាសាលាមានវត្តមានអញ្ជើញចូលរួមពីអ្នកពាក់ព័ន្ធ ក្នុងនោះមានលោកជំទាវប្រធាន គ.ក.ស.ក លោកជំទាវអភិបាលរងខេត្ត ប្រធានមន្ទីរកិច្ចការនារី និងក្រុមការងារទាំង២៥រាជធានី-ខេត្ត ដែលមានចំនួនសរុប ១៥០នាក់ ក្នុងនោះស្រី ១៣៧នាក់៕

# វគ្គបណ្ដុះបណ្ដាលស្ដីពី «ថវិកាសមិទ្ធកម្ម»








នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នៃក្រសួងកិច្ចការនារី សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាបណ្ដុះបណ្ដាលស្ដីពី « **ថវិកាសមិទ្ធកម្ម**» ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់ថ្នាក់ដឹកនាំ មន្ត្រីក្រសួង និងមន្ទីរកិច្ចការនារីរាជធានី/ខេត្ត ក្នុងការរៀបចំផែនការថវិកាឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រនារីរតនៈ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវ** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី នៅខេត្តសៀមរាប ដែលមានអ្នកចូលរួមសរុបចំនួន ១៣៧នាក់ (ស្រី១១៥នាក់ )។ វគ្គបណ្ដុះបណ្ដាលនេះប្រព្រឹត្តទៅនៅខេត្តសៀមរាប ដែលមានរយៈពេល ២ថ្ងៃ គិតចាប់ពីថ្ងៃទី១៣ ដល់ទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣។












មន្ត្រីសំខាន់ៗដែលពាក់ព័ន្ធនឹងការដោះស្រាយ
អំពើហិង្សាលើស្ត្រី និងក្មេងស្រី













# វគ្គបណ្តុះបណ្តាលស្តីពី ច្បាប់ និងឯកសារក្បួននីតិវិធីប្រតិបត្តិការ របស់មន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌





ក្រសួងកិច្ចការនារី សហការជាមួយមន្ទីរកិច្ចការនារីខេត្ត បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "**ច្បាប់ និងឯកសារក្បួននីតិវិធីប្រតិបត្តិការរបស់មន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌**" ក្រោមអធិបតីភាពរបស់លោកជំទាវ **ទេស ច័ន្ទសារឿន** អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅខេត្តបាត់ដំបង។ វគ្គបណ្តុះបណ្តាលនេះមានរយៈពេល ៣ថ្ងៃ គិតចាប់ពីថ្ងៃទី០១-០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មានការអញ្ជើញចូលរួមពីលោកជំទាវ **កែវ ដាណា** អភិបាលរងខេត្ត លោកស្រីប្រធានមន្ទីរកិច្ចការនារីខេត្តបាត់ដំបង និងមានការអញ្ជើញចូលរួមពីប្រធាន/អនុប្រធានមន្ទីរកិច្ចការនារី អភិបាល-រងក្រុង/ស្រុក ប្រធាន/អនុប្រធានការិយាល័យសុខុមាលភាពសង្គម នគរបាលប៉ុស្តិ៍ និងមន្ត្រី/ភ្នាក់ងារនគរបាល យុត្តិធម៌មកពីខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ពោធិ៍សាត់ កំពង់ឆ្នាំង សៀមរាប កណ្តាល ឧត្តរមានជ័យ និងមន្ត្រីក្រសួងកិច្ចការនារី សរុបចំនួន ៥៥នាក់ (ស្រី ៣៦នាក់) ក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពមន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងការជួយជនរងគ្រោះឱ្យបានទាន់ពេលវេលា ព្រមទាំងបំពេញភារកិច្ចរបស់ខ្លួន ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។



# សកម្មភាពការងាររបស់នាយកដ្ឋានផែនការ

•បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំផែនការស្ថិតិ ការត្រួតពិនិត្យ និងវាយតម្លៃឆ្លើយតបនឹងយេនឌ័រ ចំនួន ៣លើក នៅខេត្តកោះកុង ខេត្តស្ទឹងត្រែង និងខេត្តកំពង់ធំ ជូនដល់មន្ត្រីក្រសួង/មន្ទីរកិច្ចការនារី អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ/សង្កាត់ ក្នុងរាជធានី/ខេត្តទាំង២៥ ដែលមានអ្នកចូលរួមសរុបចំនួន ១៥១នាក់ (ស្រី ១៣១នាក់) ក្នុងគោលបំណងដើម្បីបង្កើនសមត្ថភាព ក្នុងការរៀបចំផែនការស្ថិតិ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃឆ្លើយតបនឹងយេនឌ័រប្រកបដោយប្រសិទ្ធភាព។






•បានរៀបចំកិច្ចប្រជុំអន្តរនាយកដ្ឋានចំនួន ៣លើក ដើម្បីពិភាក្សាផ្តល់ធាតុចូលសម្រាប់រៀបចំរបាយការណ៍ត្រួតពិនិត្យដោយស្ម័គ្រចិត្ត នៃការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០២៣ និងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ និងរៀបចំសូចនាករគោលដៅនិងយុទ្ធសាស្ត្រ ស្តីពី ប្រជាជន និងអភិវឌ្ឍន៍ ជូនក្រសួងផែនការ សរុបអ្នកចូលរួមមានចំនួន ១១០នាក់ (ស្រី ៩១នាក់) ។

•ខិត្តបណ្ណស្ថិតិយេនឌ័រសំខាន់ៗក្នុងប្រទេសកម្ពុជា និងឯកសារណែនាំស្តីពីការបញ្ចូលយេនឌ័រទៅក្នុងការគ្រប់គ្រងស្ថិតិពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយនៅកម្ពុជាត្រូវបានផលិត និងដាក់ឱ្យប្រើប្រាស់។

## ស្ថិតិយេនឌ័រសំខាន់ៗក្នុងប្រទេសកម្ពុជា

## (គិតត្រឹម ខែធ្នូ ឆ្នាំ២០២៣)

ខិត្តប័ណ្ណនេះ បង្ហាញនូវស្ថិតិសំខាន់ៗអំពីស្ត្រី និងបុរសនៅកម្ពុជា ព័ត៌មានដែលបានលើកយកមកបង្ហាញនៅក្នុងខិតប័ណ្ណនេះ គឺផ្អែកសំខាន់ទៅលើលទ្ធផលនៃការធ្វើជំរឿនព្រមទាំងការអង្កេតថ្នាក់ជាតិនានា និងទិន្នន័យដែលបានបោះពុម្ពផ្សាយដោយក្រសួង / ស្ថាប័នរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។

### ១. ចំនួនប្រជាជន (ឆ្នាំ២០២៣ និងជំរឿនឆ្នាំ២០១៩)

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ឃើញថាចំនួនប្រជាជននៅកម្ពុជាមានការប្រែប្រួល ពិសេសមានការកើនឡើងទាំងស្ត្រី និងបុរស ហើយស្ត្រីមានចំនួនច្រើនជាងបុរសបន្តិចបន្តួច។ នៅឆ្នាំ២០២៣ ប្រជាជនកម្ពុជាសរុបមានការកើនឡើងគួរឱ្យកត់សម្គាល់ ១៧,០៩១,៤៦៤នាក់ (ស្ត្រី៥១.១% និងបុរស៤៨.៩%)។

**ចំនួនប្រជាជនសរុបនៅកម្ពុជា (គិតជាពាន់នាក់)**




*ប្រភព: ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ក្រសួងផែនការ*

យោងតាមលទ្ធផលជំរឿនទូទៅឆ្នាំ២០១៩ ចំនួនប្រជាជនសរុបនៅកម្ពុជាមានចំនួន ១៥,៥៥២,២១១នាក់ ក្នុងនោះស្ត្រីមាន ៥១.៣% និងបុរស ៤៨.៧%។




*ប្រភព: ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ក្រសួងផែនការ*

**ចំនួនប្រជាជនបែងចែកតាមតាមភេទ និងតំបន់ភូមិសាស្ត្រ (ឆ្នាំ២០១៩)**

| តំបន់ | សរុប | ស្ត្រី | បុរស |
|---|---|---|---|
| សរុប | 15,552,211 | 7,980,374 | 7,571,837 |
| ទីប្រជុំជន | 6,135,194 | 3,141,855 | 2,993,339 |
| តំបន់ជនបទ | 9,417,017 | 4,838,519 | 4,578,498 |

*ប្រភព: ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ ក្រសួងផែនការ*

# សកម្មភាពការងាររបស់នាយកដ្ឋានសមភាពយេនឌ័រ

សកម្មភាពការងារសំខាន់ៗដែលបានអនុវត្តក្នុងឆ្នាំ ២០២៣ នេះដោយមានការគាំទ្រពីកម្មវិធី ACCESS រួមមាន៖



• ថ្ងៃទី១៦-២០ ខែមករា និងថ្ងៃទី២២-២៤ ខែកុម្ភៈ ឆ្នាំ ២០២៣ បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិស្តីពី **«ថវិកាឆ្លើយតបនឹងយេនឌ័រនៅក្នុងកម្មវិធីវិនិយោគឃុំ-សង្កាត់ (GRB in CIP)»** អ្នកចូលរួមសរុបចំនួន ៦៤នាក់ (ស្រី ៣៧នាក់) នៅសណ្ឋាគារពូលូវៃ និងសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ ។





• ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ បានរៀបចំសិក្ខាសាលាប្រចាំឆ្នាំស្តីពី **«ការបញ្ជ្រាបយេនឌ័រ បរិយាបន្ន និងសមធម៌សង្គមនៅថ្នាក់ក្រោមជាតិ»** ជាមួយមន្ទីរកិច្ចការនារីទាំង ២៥ រាជធានី-ខេត្ត ក្រោមអធិបតីភាពលោកជំទាវ **ឥម ស៊ីផាត់** រដ្ឋលេខាធិការក្រសួងកិច្ចការនារី អ្នកចូលរួមសរុបចំនួន ១០០នាក់ (ស្រី ៧៩នាក់) នៅក្រសួងកិច្ចការនារី។

• ថ្ងៃទី៣ ដល់ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣ បានរៀបចំកិច្ចប្រជុំបច្ចេកទេស និងសិក្ខាសាលាជាតិស្តីពី **«សេដ្ឋកិច្ចដែលគិតគូរពីសុខុមាលភាព និងការងារថែទាំដែលគ្មានប្រាក់កម្រៃ»** ក្រោមអធិបតីភាពលោកជំទាវកិត្តិបណ្ឌិត **អ៊ុឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ ដែលមានអ្នកចូលរួមសរុបចំនួន ៥៤នាក់ (ស្រី ៣៦នាក់) ។




• កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៣ ក្នុងកិច្ចសហការជាមួយអង្គការផ្លែនអន្តរជាតិ បានរៀបចំកម្មវិធីរត់ដើម្បីក្មេងស្រី និងដើម្បីទាំងអស់គ្នា (Run for Girls, Run for All) អបអរសាទរទិវាអន្តរជាតិក្មេងស្រី ក្រោមប្រធានបទ **«ការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ក្មេងស្រី ក្នុងយុគសម័យឌីជីថល»** នៅមជ្ឈមណ្ឌលកោះពេជ្រ មានអ្នកចូលរួមសរុបចំនួន៥០០នាក់ ។

• ក្នុងរយៈពេល១០ខែ ឆ្នាំ២០២៣នេះ តាមរយៈថវិកាកម្មវិធី PB នាយកដ្ឋានបានបើកវគ្គបណ្តុះបណ្តាលចំនួន ០៧វគ្គ រួមមាន៖

\+ រៀបចំវគ្គបណ្តុះបណ្តាលស្តីពី **«ការស្វែងរកការគាំទ្រមតិ»** ចំនួន០២វគ្គ នៅខេត្តសៀមរាប និងខេត្តកំពង់ធំ មានអ្នកចូលរួមសរុបចំនួន ១០០នាក់ (ស្រី ៧៦នាក់)។

\+ រៀបចំវគ្គបណ្តុះបណ្តាលស្តីពី **«ការលើកកម្ពស់យេនឌ័រ បរិយាបន្ន និងសមធម៌សង្គម»** ចំនួន០៣វគ្គ នៅខេត្តកែប បន្ទាយមានជ័យ និងស្វាយរៀង មានអ្នកចូលរួមសរុបចំនួន ១៥៧នាក់ (ស្រី ១៣២នាក់)។

\+ រៀបចំវគ្គបណ្តុះបណ្តាលស្តីពី **«ស្ត្រី និងភាពជាអ្នកដឹកនាំ»** ចំនួន ០២វគ្គ នៅខេត្តបាត់ដំបង និងរតនគិរី មានអ្នកចូលរួមសរុបចំនួន ១១០នាក់ (ស្រី ៨៩នាក់)៕

# សកម្មភាពការងារនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បានអនុវត្តសកម្មភាព ដោយប្រើប្រាស់ថវិកាជាតិតាមកម្មវិធី (PB)៖**

• បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ០៣លើក **ស្តីពីកិច្ចការស្ត្រី និងអាស៊ាន និងអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកិច្ចការនារី និងដៃគូអភិវឌ្ឍន៍** ដែលមានអ្នកចូលរួមសរុបចំនួន ១៣៥នាក់ (ស្ត្រី ១០២នាក់) នៅខេត្តសៀមរាប ខេត្តកំពត និងខេត្តកំពង់ធំ ។ សមាសភាពចូលរួមជាមន្ត្រីក្រសួងកិច្ចការនារីមកពី១០នាយកដ្ឋាន និងមន្ទីរកិច្ចការនារីខេត្តចំនួន២១ខេត្ត រួមមាន៖ ខេត្តសៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ស្ទឹងត្រែង ប៉ៃលិន កំពង់ធំ ក្រចេះ កំពត ព្រះសីហនុ កោះកុង កែប កំពង់ស្ពឺ តាកែវ កណ្តាល រាជធានីភ្នំពេញ ព្រៃវែង កំពង់ចាម ត្បូងឃ្មុំ ព្រះវិហារ និងខេត្តកំពង់ឆ្នាំង។



• បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ០៣លើក ស្តីពីកិច្ចប្រជុំតាមដានការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងកិច្ចការនារី និងដៃគូអភិវឌ្ឍន៍ នៅក្រសួងកិច្ចការនារី ដែលមានអ្នកចូលរួមសរុបចំនួន ១២១នាក់ (ស្រី ៩១នាក់) ក្នុងគោលបំណងដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងចែករំលែកនូវបច្ចុប្បន្នភាព ក្នុងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចសហប្រតិបត្តិការរវាងក្រសួងកិច្ចការនារី និងដៃគូអភិវឌ្ឍន៍។






**ការដឹកនាំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ**

• លោកជំទាវ **ខេង សំវ៉ាដា** បានដឹកនាំនូវកិច្ចប្រជុំក្រុមប្រឹក្សាអាស៊ានស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ( Advisory Group on WPS Meeting ) បានចំនួន ០៥ដង (ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២៣) ដែលមានអ្នកចូលរួមសរុបចំនួន ១២០នាក់ (ស្ត្រី ១១០នាក់) នៅតាម ប្រព័ន្ធវីដេអូអនឡាញ។ សមាសភាពចូលរួមមានដូចជា សមាជិករបស់ក្រុមប្រឹក្សាអាស៊ានស្តីពី ស្ត្រី សន្តិភាព និង សន្តិសុខ ( Advisory Group on WPS ) តំណាងរបស់ដៃគូអភិវឌ្ឍន៍ និងជំនាញការថ្នាក់តំបន់ ដែលបានជួបជុំគ្នាដើម្បីពិភាក្សាលើការបង្កើតឱ្យមានឧបករណ៍ និងសេចក្តីណែនាំ ក្នុងការអនុវត្តនូវផែនការសកម្មភាពថ្នាក់តំបន់ស្តីពីស្ត្រី សន្តិភាព និងសន្តិសុខ ព្រមទាំងការធ្វើមូលដ្ឋានីយកម្មនៅថ្នាក់ជាតិនៃផែនការសកម្មភាពនេះ (Toolkit and Guideline for the Localization on RPA WPS)។

**ការចូលរួមធ្វើបទអន្តរាគមន៍**

• លោកជំទាវ **គង់ សុរីតា** បានចូលរួមធ្វើជាវាគ្មិនក្នុងសិក្ខាសាលាថ្នាក់តំបន់ស្តីពី «**ការពង្រឹងភាពធន់ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងអាស៊ាន តាមរយៈការអភិវឌ្ឍផែនការសកម្មភាពលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យនយោបាយ**» មានអ្នកចូលរួមសរុបចំនួន ៤៥នាក់ (ស្ត្រី ៣៣នាក់) នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី ។

# សកម្មភាពការងាររបស់នាយកដ្ឋានស្ត្រី និងសុខភាព

រយៈពេល១០ខែក្នុងឆ្នាំ២០២៣នេះសកម្មភាពការងាររបស់នាយកដ្ឋានស្ត្រី និងសុខភាព រួមមាន៖

• បានផលិតស្ពតវីដេអូខ្លីៗចំនួន ៧ ស្តីពី**ជំងឺមហារីកសុដន់ ជំងឺមហារីកមាត់ស្បូន អាហារូបត្ថម្ភ សុខភាពភ្នែក** និងចាក់ផ្សាយតាមទូរទស្សន៍ទាំង១០ ដែលមានអ្នកទស្សនារាប់ម៉ឺននាក់។





•បានរៀបចំយុទ្ធនាការអប់រំសហគមន៍ស្តីពី **សុខភាពភ្នែក "កំហុសកំណុំរូបភាព" និងជំងឺបាយភ្នែក ជំងឺកន្ទុយថ្លែនរបួសភ្នែក ជំងឺភ្នែកក្រហម** ដល់ប្រជាជននៅក្នុងខេត្តចំនួន៦ ឧបត្ថម្ភគាំទ្រដោយមូលនិធិហ្វ្រេតហូឡូ (FHF) មានចំនួន ៣៥ដង សរុបអ្នកចូលរួមចំនួន ៦៦៥៧នាក់ (ស្ត្រី ៥៧៩៧ នាក់) និងបានរៀបចំយុទ្ធនាការស្តីពី ជំងឺមហារីកសុដន់ ជំងឺមហារីកមាត់ស្បូន អាហារូបត្ថម្ភ និងចំណេះដឹងហិរញ្ញវត្ថុ ដល់ប្រជាជននៅក្នុងខេត្តចំនួន ៤ខេត្ត ឧបត្ថម្ភគាំទ្ររបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត AIA មានចំនួន ៤៤ដង សរុបអ្នកចូលរួមចំនួន ៨៩១៦នាក់ (ស្រី ៨២០៣នាក់)។









•បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៣វគ្គ ស្តីពីជំងឺមិនឆ្លង (ជំងឺមហារីកសុដន មហារីកមាត់ស្បូន ជំងឺលើស-សម្ពាធឈាម ទឹកនោមផ្អែម ជំងឺភ្នែក) និងវគ្គការកសាងទំនាក់ទំនងមាតា និងយុវតី ស្តីពីសុខភាពបន្តពូជ ជំងឺឆ្លងកាមរោគ/ជំងឺអេដស៍ អាហារូបត្ថម្ភ នៅខេត្តរតនៈគីរី ខេត្តកោះកុង និងខេត្តកំពង់ឆ្នាំង ឧបត្ថម្ភថវិកាតាមកម្មវិធី (PB) ក្នុងខេត្តគោលដៅចំនួន២៤ខេត្ត បានចំនួន ៣ ដង សរុបអ្នកចូលរួមចំនួន ១៤៥នាក់ (ស្ត្រី ១៣២នាក់)៕

# សកម្មភាពការងាររបស់នាយកដ្ឋានព័ត៌មាន




*លោកជំទាវ ប៊ុន ពុទ្ធី រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី ជាគណៈអធិបតី នៅវិទ្យាល័យ នេត យ៉ង់ ខេត្តបាត់ដំបង*

បានរៀបចំវេទិកានារីរតនៈ ស្តីពី ***យុវជនរួមគ្នាកាត់បន្ថយអំពើហិង្សា*** នៅវិទ្យាល័យចំនួន០៩ របស់ខេត្តប៉ៃលិន សៀមរាប និងខេត្តបាត់ដំបង ដើម្បីបង្កើនការយល់ដឹងរបស់យុវវ័យរួមគ្នាកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងសង្គម ដែលមានអ្នកចូលរួមមកពីមន្ទីរកិច្ចការនារីខេត្ត មន្ទីរអប់រំយុវជន និងកីឡា អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សសរុបចំនួន ១.៣៧៧នាក់ (ស្ត្រី ៨៩១នាក់) ៕



*សិស្សនៅវិទ្យាល័យបាយ័ន ខេត្តសៀមរាប*



*សកម្មភាពគណៈធិបតីថតរូបអនុស្សាវរីយ៍ជាមួយសិស្សានុសិស្ស*
*លើកដៃស្តាំជាសញ្ញាបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី នៅវិទ្យាល័យសាលាក្រៅ ខេត្តប៉ៃលិន*

# សកម្មភាពរបស់នាយកដ្ឋានការពារផ្លូវច្បាប់

### ១. សកម្មភាពការងារទប់ស្កាត់អំពើហិង្សាលើស្ត្រី

•កិច្ចប្រជុំក្រុមការងារបច្ចេកទេសឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ។



•យុទ្ធនាការ១៦ថ្ងៃ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី។



•វេទិកាផ្សព្វផ្សាយថ្នាក់ភូមិតាមរយៈខ្សែវីដេអូស្តីពីឥទ្ធិពលនៃការផ្លាស់ប្តូរបុរសល្អ។

•វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។



### ២. សកម្មភាពការងារទប់ស្កាត់ការរំលោភ

•វគ្គបណ្តុះបណ្តាលស្តីពី ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រីនឹងក្មេងស្រី។

•វេទិកាផ្សព្វផ្សាយស្តីពី ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រីនឹងក្មេងស្រី។



### ៣. សកម្មភាពការងារផ្នែកច្បាប់

•កិច្ចប្រជុំផែនទីតម្រង់ទិសឆ្ពោះទៅធ្វើវិសោធនកម្មច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

•វគ្គបណ្តុះបណ្តាលស្តីពី ច្បាប់ និងឯកសារក្បួននីតិវិធីប្រតិបត្តិការរបស់មន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌ ។

### ៤. សកម្មភាពការងារទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ

• កិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារខេមមីតកម្ពុជា។

•កិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់ក្នុងការអនុវត្តកម្មវិធីសុវត្ថិភាព និងយុត្តិធម៌ ដើម្បីលើកកម្ពស់សិទ្ធិ និងឱកាស សម្រាប់ពលករទេសន្តរប្រវេសន៍ជាស្ត្រីនៅក្នុងតំបន់អាស៊ាន។

•វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពី "ការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន" នៅខេត្តមណ្ឌលគិរី ។

•វេទិកាផ្សព្វផ្សាយដល់ប្រជាជន ស្តីពី"សកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន" នៅភូមិប៉ាខេ ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។

•វគ្គបណ្តុះបណ្តាលគ្រូបង្គោល (ថ្នាក់តំបន់) ស្តីពី "លើកកម្ពស់ការចូលរួមរបស់អ្នកម្តាយ ដើម្បីទប់ស្កាត់ការប្រើប្រាស់ និងចែកចាយគ្រឿងញៀន" នៅខេត្តព្រះវិហារ។

•វេទិកាផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋថ្នាក់ភូមិ ស្តីពី "លើកកម្ពស់ការចូលរួមរបស់អ្នកម្តាយ ដើម្បីទប់ស្កាត់ការប្រើប្រាស់ និងចែកចាយគ្រឿងញៀន"នៅឃុំឈានមុខ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។

# សកម្មភាពការងាររបស់នាយកដ្ឋានស្ត្រី និងការអប់រំ

• បានផ្សព្វផ្សាយនៅសហគមន៍លើឧបករណ៍សកល (កម្រិតទី១) ស្តីពី «**ការចិញ្ចឹមកូនបែបវិជ្ជមាន**» នៅខេត្ត កណ្តាល បាត់ដំបង ព្រះសីហានុ សៀមរាប ព្រៃវែង ក្រចេះ និងរាជធានីភ្នំពេញ អ្នកចូលរួមសរុបចំនួន ២.៦៥៧នាក់ (ស្រី ១.៦៣៨នាក់) ។



• អនុប្រធាន និងមន្ត្រីមន្ទីរកិច្ចការនារី មន្ត្រីការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម មេឃុំ គ.ក.ន.ក មេភូមិ សមាជិកភូមិ និងអ្នកស្ម័គ្រចិត្តភូមិសរុបចំនួន ២០៤នាក់ (ស្រី ១៧១នាក់) នៃខេត្តរតនគិរី ព្រៃវែង ក្រចេះ សៀមរាម បាត់ដំបង ព្រះសីហានុ បន្ទាយមានជ័យ កណ្តាល និង រាជធានីភ្នំពេញ បានទទួលចំណេះដឹង និងរបៀបសម្របសម្រួលលើមេរៀនស្តីពី «**សុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ**»។



• បានរៀបចំវេទិកាពិគ្រោះយោបល់ស្តីពី ការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យអប់រំ ក្រោមប្រធានបទ « **ខ្ញុំមិនភ័យខ្លាច**» អ្នកចូលរួមសរុបចំនួន ៩៩០នាក់ ( ស្រី ២៨៣នាក់) នៅតាមវិទ្យាល័យក្នុងស្រុកវាលវែង ស្រុកភ្នំក្រវាញ និង ស្រុកក្រគរ នៃខេត្តពោធិ៍សាត់។

• បានបើកវគ្គបណ្តុះបណ្តាលស្តីពី «សុខុមាលភាពសង្គម» នៅខេត្តតាកែវ និងខេត្តរតនគិរី សរុបចំនួន ១១០នាក់ (ស្រី ៩៤នាក់ ) មកពីនាយកដ្ឋានពាក់ព័ន្ធក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីខេត្ត៖ ខេត្តកោះកុង កំពងស្ពឺ ព្រះសីហានុ បាត់ដំបង កែប កំពត កណ្តាល រាជធានី ភ្នំពេញ ព្រៃវែង ស្វាយរៀង កំពង់ចាម ក្រចេះ ត្បូងឃ្មុំ ស្ទឹងត្រែង រតនគិរី តាកែវ និងខេត្តព្រះវិហារ។

• ថ្នាក់ដឹកនាំក្រសួង មន្ត្រីនាយកដ្ឋានពាក់ព័ន្ធក្រសួងកិច្ចការនារី ថ្នាក់ដឹកនាំ និងមន្ត្រីមន្ទីរកិច្ចការនារីខេត្ត៖ ខេត្តកោះកុង ព្រះសីហានុ កំពងស្ពឺ បាត់ដំបង កែប កំពត កណ្តាល រាជធានីភ្នំពេញ ព្រៃវែង ស្វាយរៀង កំពង់ចាម ក្រចេះ ត្បូងឃ្មុំ ស្ទឹងត្រែង រតនគិរី តាកែវ និងខេត្តព្រះវិហា សរុបចំនួន ១១០នាក់ (ស្រី ៩៤នាក់) បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី «សុខុមាលភាពសង្គម» នៅខេត្តតាកែវ និងខេត្តរតនគិរី។

• មន្ត្រីមន្ទីរកិច្ចការនារី ក្រុមប្រឹក្សាស្រុក ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ឃុំ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ អ្នកស្ម័គ្រចិត្តភូមិក្នុងស្រុកឈូក និងស្រុកជុំគីរី សរុបចំនួន ៩៥នាក់ (ស្រី ២៩នាក់) បានទទួលចំណេះដឹងទាក់ទងនឹងការចិញ្ចឹមកូនបែបវិជ្ជមាន និងសុវត្ថិភាពកុមារលើប្រព័ន្ធអនឡាញ គុណសម្បត្តិអ្នកសម្របសម្រួល និងរបៀបសម្របសម្រួលមេរៀន ដើម្បីពួកគាត់មានសមត្ថភាព លទ្ធភាពពេញលេញសម្រាប់គាំទ្រដល់ដំណើរការអនុវត្តគម្រោងស្តីពី ការចិញ្ចឹមកូនបែបវិជ្ជមាន។



• ថ្នាក់ដឹកនាំជារដ្ឋលេខាធិការ និងក្រុមការងារ ព្រមទាំងមន្ត្រីខុទ្ទកាល័យ ក្រសួងកិច្ចការនារីសរុបចំនួន ២៧នាក់ (ស្រី ២៥នាក់) បានទទួលគណៈប្រតិភូក្រសួងរៀបចំដែនដី នគរូបណីយ៍កម្ម និងសំណង់ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងមុខងារសាធារណៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការទស្សនពិភពលោកមកទស្សនកិច្ចសិក្សាស្វែងយល់ពីការរៀបចំ និងដំណើរការថ្នាក់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូនរបស់ក្រសួងកិច្ចការនារី៕

# សហគមស្ត្រីផលិតក្រឡាន ដែលមានគុណភាពល្អ និងរសជាតឈ្ងុយឆ្ងាញ់ នៅឃុំថ្មគ្រែ ស្រុកចិត្តបុរី ខេត្តក្រចេះ

**ក្រឡាន នៅឃុំថ្មគ្រែលើ ស្រុកចិត្តបុរី ខេត្តក្រចេះ គឺជាក្រឡានដែលមានលក្ខណៈពិសេសខុសពីខេត្តផ្សេង មានរសជាតិឈ្ងុយឆ្ងាញ់ ទន់ល្អតបែបធម្មជាតិដោយប្រើខ្ទិះដូង**



**សុទ្ធ (ខ្ទិះដើម) មានជើងខ្លី សំបកស្តើង ។**

លោកស្រី **មុំចាន់ធូ** ជាអ្នកទទួលទិញផលិតផលក្រឡានពីសហគមន៍ផលិតក្រឡាន ឃុំថ្មគ្រែលើ ស្រុកចិត្តបុរី ខេត្តក្រចេះបានលើកឡើងថា ៖ ហេតុផលដែលលោកស្រីទទួលទិញផលិតផលក្រឡានរបស់សហគមន៍ស្ត្រីផលិតក្រឡានឃុំថ្មគ្រែលើ ស្រុកចិត្តបុរី ខេត្តក្រចេះនេះ « *ទី១. លោកស្រីចង់លើកស្ទួយផលិតផលក្រឡានដែលជាស្នាដៃពីដូនតាប្រចាំខេត្តក្រចេះ ចង់ឱ្យអ្នកមកលេងក្រចេះ ឬអ្នកទេសចរ គេនឹកឃើញថា ខេត្តក្រចេះមានអ្វីគួរឱ្យចាប់អារម្មណ៍នោះគឺក្រឡានក្រចេះដែលជានិមិត្តរូបប្រចាំខេត្ត។ ទី២.ក្រឡានក្រចេះ មានរសជាតិឈ្ងុយឆ្ងាញ់ទន់ល្អតបែបធម្មជាតិដោយប្រើខ្ទិះដូងសុទ្ធ(ខ្ទិះដើម) មានជើងខ្លី សំបក*



*ស្តើង មានលក្ខណៈពិសេសខុសពីខេត្តផ្សេង។ទី៣. ដើម្បីជួយបង្កើនមុខរបរដល់ស្ត្រីនៅតាមសហគមន៍ ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុក* »។

លោកស្រី **អ៊ឹម ណារី** ជាស្ត្រីមេម៉ាយម្នាក់ដែលរស់នៅឃុំថ្មគ្រែលើ ស្រុកចិត្តបុរី ខេត្តក្រចេះបានលើកឡើងថា៖ លោកស្រីពិតជាសប្បាយចិត្តខ្លាំងណាស់ ដែលមានសហគមន៍ផលិតក្រឡាននេះ ព្រោះថាតាំងពីប្តីលោកស្រីស្លាប់ទៅ លោកស្រីមិនមានលទ្ធភាពក្នុងការផលិតក្រឡានដោយខ្លួនឯងបានទេ ព្រោះថាការផលិតក្រឡានត្រូវការចំណាយពេល កម្លាំង និងដើមទុនច្រើនក្នុងការធ្វើវា ។ « *យើងត្រូវចំណាយកម្លាំងក្នុងការទៅកាប់បំពង់ឫស្សី ចំណាយកម្លាំងដើម្បីសកបំពង់ឫស្សី ចំណាយកម្លាំងរលីងដូង និងកោសដូង និងចំណាយកម្លាំងដុតទៀតផងយ៉ាងហោចណាស់យើងក៏ត្រូវមានមនុស្ស ៣ទៅ៤នាក់ដែរបានអាចធ្វើទៅបានតាមតម្រូវការ និងទាន់ទីផ្សារគេ*»។

លោកស្រីបានបន្តទៀតថា៖ សព្វថ្ងៃលោកស្រីមកធ្វើការឱ្យសហគមន៍នេះ ដោយធ្វើតែលើផ្នែករលីង និងកោសដូង



ប៉ុណ្ណោះ ក្នុងមួយថ្ងៃលោកស្រីអាចរកប្រាក់ចំណូលបានពី ៤០.០០០រៀល ទៅ ៥០.០០០រៀល ដោយមិនបាច់ចំណាយដើមទុន ហើយមានពេលច្រើនអាចធ្វើការងារផ្ទះ និងមើលថែទាំកូនចៅទៀតផង។



លោកស្រី **ឆូ គមសិត** ប្រធានមន្ទីរកិច្ចការនារីបានលើកឡើងថា៖ ដើម្បីឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺផ្តោតលើ ការពង្រឹង ស្ថាប័ន និងគុណភាពការងារ ដើម្បីរួមចំណែកលើកស្វួយស្ថានភាពស្ត្រីដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ ជាពិសេសអោយស្របតាមទាន់សម័យកាលឌីជីថល។ ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី គឺជាយន្តការ សម្រាប់ជម្រុញ និងលើកកម្ពស់សមភាពយេនឌ័រ និង បរិយាបន្ន ការបង្កើន



ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី មន្ទីរដើរតួយ៉ាងសំខាន់ក្នុងការជំរុញស្វែងរកការគាំទ្រមតិ ការទំនាក់ទំនង និងការសម្របសម្រួលដល់មន្ទីរពាក់ពន្ធ័ និងដៃគូរអភិវឌ្ឍន៍ ដើម្បីបង្កើនការចូលរួមរបស់ស្ត្រីលើវិស័យសេដ្ឋកិច្ច។

ក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារី បានធ្វើការងារពង្រឹងផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី តាមរយៈការលើកកម្ពស់ការធ្វើអាជីវកម្មខ្នាតតូច ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី អប់រំផ្សព្វផ្សាយដល់ស្ត្រី ឱ្យចេះធ្វើការសម្របខ្លួនទៅនិងការប្រែប្រួលអាកាសធាតុ ជំរុញ និងបង្កើនការដាំដុះ ដើម្បីកាត់បន្ថយការចំណាយ។ល។

មន្ទីរកិច្ចការនារីខេត្តក្រចេះ ក៏បានរួមចំណែកក្នុងការផ្តល់ជាគំនិតនិងធាតុចូលមួយចំនួនក្នុងការចងក្រងជាសហាគមន៍ស្ត្រីផលិតក្រឡាននេះឡើង ក្នុងគោលបំណងជួយដល់ស្ត្រី ពិសេសស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ និងស្ត្រីចាស់ៗអាចមានការធ្វើ និងមានប្រាក់ចំណូលអាចជួយសេដ្ឋកិច្ចគ្រួសារបានបន្ថែមទៀតក្រៅពីការងារកសិកម្មរបស់ពួកគាត់ និងអាចកាត់បន្ថយការធ្វើចំណាកស្រុកផងដែរ៕

# សិប្បកម្មតម្បាញហូលលក្ខណ៍ខ្មែរ





ម្ចាស់សិប្បកម្មតម្បាញហូលលក្ខណ៍ខ្មែរ អ្នកស្រី **អ៊ូ ស្រីអូន** អាយុ៣៩ឆ្នាំ រស់នៅក្នុងភូមិកញ្ជាង ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ មានកីតម្បាញចំនួន១៦កី និងមានបុគ្គលិក ២៦នាក់។ អ្នកស្រីបានមានប្រសាសន៍ថា មុខរបរមួយនេះទាមទារឱ្យមានការអត់ធ្មត់ខ្ពស់ ដោយសារតែគ្រប់ដំណាក់កាលនីមួយៗ នៃការផលិតត្រូវប្រើរយៈពេលយូរ និងពិបាកធ្វើជាអាទិ៍ ការជ្រលក់ពណ៌ ត្រល់សូត្រ ការខាលកៀត ការចងគោម ការត្បាញ ជាដើម..។ល។ នៅក្នុងហូលលក្ខណ៍ខ្មែរ ១ក្បិនចំណាយរយៈពេល រហូតដល់ ១ខែ ទើបអាចផលិតរួច ប៉ុន្តែសម្រាប់សិប្បកម្មទ្រង់ទ្រាយធំ និងមានបុគ្គលិកច្រើនដូចជា សិប្បកម្មរបស់អ្នកស្រីចំណាយរយៈពេល ១សប្តាហ៍ រហូតដល់ ១២ថ្ងៃទៅតាមប្រភេទគោម។ ហេតុផល ដែលអ្នកស្រីជំនះឧបសគ្គ និងការលំបាកជាច្រើនក្នុងការប្រកបមុខរបរនេះតាំងពីឆ្នាំ ២០០៦ រហូតមកដល់បច្ចុប្បន្ន គឺដោយសារតែហេតុផលសំខាន់ៗ៣៖ ជារប្បធម៌កេរ្តិ៍តំណែលដូនតា និងត្រូវតែអភិរក្សបន្ត អាចផ្តល់ការងារឱ្យប្រជាជននៅក្នុងភូមិធ្វើ ទោះបីជាពួកគាត់មានវ័យចំណាស់អាយុ ៧០ឆ្នាំក៏ដោយ និងផ្តល់ប្រាក់ខែជូនពួកគាត់ចន្លោះពី ១៥០ដុល្លារ ទៅ ២០០ដុល្លារ ក្នុង ១ខែ ជាមុខរបរគោលសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារឱ្យប្រសើរឡើង។ បច្ចុប្បន្នហូលដែលសិប្បកម្មរបស់ **ស្រីអូន** បានផលិតសុទ្ធតែជាទំនិញ ដែលហាងល្បីៗធំៗនៅទីក្រុងភ្នំពេញបានកម្មង់ និងមានកុងត្រា។ អ្នកស្រីក៏មានបំណងពង្រីកទីផ្សារ ទៅកាន់ខេត្តផ្សេងៗទៀត និងបរទេសផងដែរ (សហរដ្ឋអាមេរិក និងអង់គ្លេស) ដើម្បីឱ្យប្រជាជនខ្មែរ និងជនបរទេសកាន់តែច្រើនបានស្គាល់ និងប្រើប្រាស់ហូលលក្ខណ៍ខ្មែរ ដែលជាក្រណាត់ដ៏អស្ចារ្យ ផលិតចេញពីក្តីស្រលាញ់ និងចិត្តអត់ធ្មត់របស់ស្ត្រីខ្មែរ៕ ***ណារី***



# ស្ត្រី និងរបរកែច្នៃវត្ថុអនុស្សាវរីយ៍ផលិតពីស្លឹកត្នោត



វត្ថុអនុស្សាវរីយ៍ជាច្រើនដែលបានផលិតចេញពីស្លឹកត្នោត ដូចជា ស្មុគ ប្រអប់កាដូ និងផ្លិត ជាដើម ត្រូវបានដាក់លក់នៅលើទីផ្សារទាំងក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្ត។ អ្នកស្រី **ឌុល ណាំ** ជាអាជីវករមួយរូបរស់នៅក្នុងភូមិដំណាក់ត្រយឹង ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ និងមានក្រុមផលិតវត្ថុអនុស្សាវរីយ៍ ដែលធ្វើអំពីស្លឹកត្នោតរហូតដល់ជិត ១០០នាក់ (៦ភូមិ)។ អ្នកស្រីបានប្រាប់ថា នៅក្នុង ១សប្តាហ៍ក្រុមផលិតអាចទទួលបានចំណូលពី ៧ម៉ឺនរៀល ទៅ ១០ម៉ឺនរៀល ដែលជាចំណូលបន្ទាប់បន្សំពីមុខរបរផ្សេងទៀត។ ម្យ៉ាងទៀតជីដូនដែលមើលថៃចៅៗនៅផ្ទះ ក៏អាចធ្វើការងារនេះបានដែរ ពីព្រោះជាការងារដែលមិនប្រើកម្លាំងខ្លាំង និងអាចធ្វើនៅផ្ទះខ្លួនឯងបាន ដោយចាប់ផ្តើមពីការប្រមូលទិញស្លឹកត្នោត កូដស្លឹកត្នោតជ្រលក់ពណ៌ និងត្បាញ ជាវត្ថុអនុស្សាវរីយ៍ តាមការកម្មង់របស់ភ្ញៀវ។ សម្រាប់តម្លៃវិញ គឺខុសគ្នាតិចតួចទៅតាមគុណភាពដែលភ្ញៀវកម្មង់។ បច្ចុប្បន្នអ្នកស្រី **ឌុល ណាំ** មានការកម្មង់ និងបោះដុំនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ចាម សៀមរាប កោះកុង និងប្រទេសបារាំង ផងដែរ។ មុខរបរមួយនេះទាមទារឱ្យមានការស្រឡាញ់ និងអភិរក្សដើមត្នោតផងដែរ៕ ***ណារី***







# ស្ត្រីក្នុងភាពជាអ្នកដឹកនាំស្ថិតនៅក្នុងភូមិភាគឥសាន្ត





លោកស្រី **ខ្វាន់ ព្រែល** មានអាយុ៥០ឆ្នាំ ជាមេឃុំ សែន-មនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ។ លោកស្រីជាជនជាតិដើមភាគតិចពូនង នៅភូមិពូតាំង ឃុំសែនមនោរម្យ ស្រុកអូររាំង មានកូន ៤នាក់ ស្វាមីជាយោធា ស្រុកអូររាំង។

លោកស្រីមានប្រសាសន៍ថា៖ មុននឹងក្លាយជាមេឃុំ លោកស្រីជាអ្នកស្ម័គ្រចិត្តភូមិផ្សព្វផ្សាយសុខភាពមាតា និងទារក ។ ក្នុងឆ្នាំ២០០៤ ទទួលបន្ទុកកិច្ចការនារីឃុំ ។ ឆ្នាំ២០០៧ ឈរឈ្មោះក្រុមប្រឹក្សាឃុំ បានជាប់ជាសមាជិកក្រុមប្រឹក្សាឃុំ ។ នៅឆ្នាំ២០១២ បានជាប់ជាមេឃុំរហូតដល់សព្វថ្ងៃ ក៏ដោយសារមានការគាំទ្រពីថ្នាក់ដឹកនាំ និងក្រុមគ្រួសារ និងមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងដឹកនាំ បម្រើប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាទាន់ពេលវេលា ប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព។

លោកស្រីបានបន្តថា នៅក្នុងអាណត្តិ ដែលលោកស្រីដឹកនាំ គឺមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដែលទទួលបានលទ្ធផលដូចជា ៖ ផ្លូវបេតុង ៣.៧០០ម៉ែត្រ និងផ្លូវចាក់គ្រួសក្រហម១ខ្សែ ព្រមទាំងវត្តអារាម សាលារៀន។

សូមផ្តាំផ្ញើដល់ស្ត្រីទាំងឡាយ មុននឹងក្លាយជាថ្នាក់ដឹកនាំ ឪពុកម្តាយត្រូវបញ្ជូនកូនស្រីទៅរៀនឱ្យមានចំណេះដឹងខ្ពស់ ស្ត្រីត្រូវមានឆន្ទៈ ចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ និងកិច្ចការសង្គមឱ្យបានច្រើន និងចេះប្រើកុំព្យូទ័រ ។

លោកស្រី **ម៉ាលី សុខនី** ប្រធានមន្ទីរកិច្ចការនារីខេត្តមណ្ឌលគិរី បានមានប្រសាសន៍ថា៖ មន្ទីរកិច្ចការនារីបានចូលរួមចំណែកឱ្យស្ត្រីក្លាយជាអ្នកដឹកនាំ តាមរយៈការបើកវគ្គបណ្តុះបណ្តាល កិច្ចប្រជុំផ្សព្វផ្សាយនានាទាំងថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ ដូចជា៖ការបញ្ជ្រាបយេនឌ័រ យេនឌ័រ និងជីវចម្រុះ យេនឌ័រ និងសុខភាព យេនឌ័រ និងការអប់រំ ហើយក្នុងនោះដែរ មានច្បាប់នានា ដូចជា ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ច្បាប់ប្រឆាំងការជួញដូរមនុស្ស ។ល។ ធ្វើយ៉ាងណាដើម្បីឱ្យពួកគាត់ទទួលបាននូវចំណេះដឹង មានសមត្ថភាព និងមានគុណសម្បត្តិគ្រប់គ្រាន់ ក្នុងការឈានទៅរកភាពជាអ្នកដឹកនាំ។

ជាចុងក្រោយលោកស្រី សូមផ្តល់អនុសាសន៍ដល់មាតាបិតាគ្រប់រូប ដើម្បីឱ្យស្ត្រីឬកូនស្រីក្លាយជាអ្នកដឹកនាំបាន សូមជម្រុញកូនឱ្យទៅរៀន ជាពិសេសកូនស្រី ដោយសារកន្លងមកឪពុកម្តាយមិនសូវផ្តល់ឱកាសឱ្យកូនស្រីបានរៀនសូត្រខ្ពង់ខ្ពស់ដូចកូនប្រុសទេ ហើយក៏សូមជម្រុញ និងគាំទ្រដល់សិស្សស្រី ដើម្បីឱ្យទទួលបានការអប់រំយ៉ាងតិចថ្នាក់ទី១២។ ស្ត្រី និងក្មេងស្រី ត្រូវមានភាពរឹងមាំ មានចំណេះដឹងផ្នែកភាសាបរទេស និងបច្ចេកវិទ្យា ដែលជាគ្រឹះដ៏សំខាន់ក្នុងការអភិវឌ្ឍគ្រួសារ និងសង្គមជាតិ។

លោកជំទាវ **អ៊ុត សន** សមាជិកក្រុមប្រក្សាខេត្តមណ្ឌល-គិរី បានមានប្រសាសន៍ថា៖ ក្នុងនាមជាស្ត្រីមួយរូបបាន



តទៅទំព័រ៤២

# « សមាគមស្ត្រីកែច្នៃផលិតផលគ្រឿងសមុទ្រ»



នៅក្នុងភូមិ២ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ក្រុមស្ត្រីបានចងក្រងបង្កើតឱ្យមានសមាគមមួយឈ្មោះថា «**សមាគមស្ត្រីកែច្នៃផលិតផលគ្រឿងសមុទ្រ**» ។ សមាគមនេះបង្កើតឡើងក្នុងគោលបំណងជួយដល់ស្ត្រី ក៏ដូចជាប្រជាពលរដ្ឋដែលរស់នៅតំបន់ក្បែរសមុទ្រឱ្យងាកមកប្រកបមុខរបរកែច្នៃគ្រឿងសមុទ្រ ដែលជាមុខរបរមានសក្ដានុពលក្នុងតំបន់ដែលគាត់រស់នៅ ដើម្បីបង្កើនប្រាក់ចំណូលរស់នៅជួបជុំគ្រួសារ និងចៀសវាងការធ្វើចំណាកស្រុក។



លោកស្រី **នេព និមល** ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ខេត្តព្រះសីហនុ បានមានប្រសាសន៍ថា មន្ទីរកិច្ចការនារី និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី គឺសុទ្ធសឹងតែកំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និង បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ជាពិសេសស្ត្រីដែលរស់នៅតាមជនបទ ដើម្បីឱ្យពួកគាត់ទទួលបាននូវឱកាសចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ ក្នុងការបង្កើនប្រាក់ចំណូលសមរម្យតាមរយៈការអភិវឌ្ឍអាជីវកម្មប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍ តាមរយៈការផ្ដល់នូវវគ្គបណ្ដុះបណ្ដាលធនធានមនុស្សប្រកបដោយគុណភាពជាពិសេសត្រូវធ្វើយ៉ាងណាឱ្យជំនាញនេះ ឆ្លើយតបទៅនឹងទីផ្សារបច្ចុប្បន្ន។

ក្រោមការដឹកនាំរបស់សម្ដេចតេជោនាយករដ្ឋមន្ត្រី ដែលជានិច្ចកាលបានផ្ដល់ការគាំទ្រលើកទឹកចិត្ត ការពារសិទ្ធិ និងផលប្រយោជន៍របស់ស្ត្រី និងក្មេងស្រី ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រផ្ដោតយ៉ាងជាក់លាក់ទៅលើការលើកកម្ពស់សមភាពយេនឌ័រ ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងការអភិវឌ្ឍន៍ធនធានមនុស្ស ដោយសម្ដេចទទួលស្គាល់ថា៖ « ស្ត្រីគឺជាឆ្អឹងខ្នងដ៏រឹងមាំ នៃសេដ្ឋកិច្ច និងសង្គមជាតិរបស់យើងទាំងអស់គ្នា»។

លោកស្រី **ឃីវ ពៅរ៉ា** ប្រធានគណកម្មាធិការស្ត្រី និងកុមារ (គកសក) និងជាសមាជិកក្រុមប្រឹក្សាស្រុកស្ទឹងហាវ ក៏បានលើកឡើងដែរថា សមាគមស្ត្រីកែច្នៃគ្រឿងសមុទ្របានបង្កើនឡើងនៅក្នុងឆ្នាំ២០១៨ ដើម្បីជួយក្នុងការប្រមូលផលិតផលគ្រឿងសមុទ្រដែលកែច្នៃរួចយកមកដាក់លក់នៅក្នុងតម្លៃសមរម្យ និងជួយបង្កើតឱកាសការងារសម្រាប់វិស័យនេះ។ ហេតុផលដែលលោកស្រី អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូពាក់ព័ន្ធ ផ្ដួចផ្ដើមឱ្យមានសមាគមនេះ ដោយសារតែមើលឃើញថាស្រុកស្ទឹងហាវជាតំបន់សមុទ្រ មានការប្រមូលផល នៃផលិតផលសមុទ្រស្រស់ៗជារៀងរាល់ថ្ងៃ ហេតុនេះការជំរុញឱ្យមានការកែច្នៃផលិតផលគ្រឿងសមុទ្រជាសក្ដានុពលរបស់ស្រុកស្ទឹងហាវ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះលោកស្រីមើលឃើញថា ស្ត្រីដែលធ្វើការក្នុងវិស័យនេះមានប្រាក់ចំណូលសមរម្យដែលអាចផ្គត់ផ្គង់ជីវភាពគ្រួសារបានគ្រប់គ្រាន់បានរស់នៅជួបជុំគ្រួសារ មើលថែកូននៅផ្ទះ និងបានឱ្យកូនទៅសាលារៀន ហើយពួកគាត់អាចជៀសផុតពីការចំណាកស្រុកទៀតផង។



បច្ចុប្បន្នលោកស្រី និងថ្នាក់ដឹកនាំស្រុកស្ទឹងហាវ កំពុងតែពិភាក្សា និងពិនិត្យមើលលទ្ធភាពក្នុងការពង្រីកទីផ្សារ

តទៅទំព័រ៤២

# ស្ត្រីក្នុងភាពជាអ្នកដឹកនាំក្រុមប្រឹក្សាឃុំ-សង្កាត់



លោកស្រី **សុខ ណារិទ្ធ** ជាប្រធានក្រុមប្រឹក្សាឃុំរំចេក ស្រុកមេមុត ខេត្តត្បូងឃ្មុំ អស់រយៈពេល ២ អាណត្តិ។ លោកស្រីជាប់ជាប្រធានក្រុមប្រឹក្សាឃុំ ដោយសារលោកស្រី គឺជាថ្នាក់ដឹកនាំវ័យក្មេងមួយរូបដែលមានភាពទទួលខុសត្រូវខ្ពស់ ធ្វើការមិនប្រកាន់បក្សពួក ចេះលើកទឹកចិត្តមន្ត្រីនៅក្រោមឱវាទ និងមានផែនការច្បាស់លាស់ ដឹកនាំប្រកបដោយតម្លាភាព មានឆន្ទៈក្នុងការបម្រើជាតិ និងសង្គមទៀតផង។

លោកស្រី **សុខ ណារិទ្ធ** មានអាយុ ៣៨ឆ្នាំ មានស្រុកកំណើតនៅខេត្តក្រចេះ តែលោកស្រីមករស់នៅស្រុកកំណើតស្វាមី ក្នុងឃុំរំចេក ខេត្តត្បូងឃ្មុំ ។

លោកស្រីបានមានប្រសាសន៍ថាមុននឹងក្លាយជាប្រធានក្រុមប្រឹក្សាឃុំ នៅឆ្នាំ២០០៨ ជាអ្នកស្ម័គ្រចិត្តផ្សព្វផ្សាយជម្ងឺគ្រុនចាញ់របស់មន្ទីរកិច្ចការនារី ។ឆ្នាំ២០០៩ ជាបុគ្គលិកអង្គការសង្គ្រោះពិភពលោក ។ឆ្នាំ២០១០ជាគ្រូជាប់កិច្ចសន្យាសាលាបឋមសិក្សាកន្ទួត។ ឆ្នាំ២០១១ មន្ត្រីជាប់កិច្ចសន្យាទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ។ នៅឆ្នាំ២០១២ អាណត្តិទី៣ លោកស្រីបានឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយបានជាប់ជាសមាជិកក្រុមប្រឹក្សាឃុំ ។ ក្នុងឆ្នាំ២០១៧ អាណត្តិទី៤ លោកស្រីបានឈរឈ្មោះបន្តទៀត ទើបបានជាប់ជាប្រធានក្រុមប្រឹក្សាឃុំរហូតមកដល់បច្ចុប្បន្ន ។

លោកស្រីបន្តថា ទម្រាំបានដល់សព្វថ្ងៃ លោកស្រីមានការតស៊ូមតិជាច្រើន ដើម្បីលើកយកបញ្ហារបស់ប្រជាពលរដ្ឋ និងសំណូមពរទៅដាក់ជូនអង្គប្រជុំ ឬក៏សម្របសម្រួលណាមួយឱ្យអង្គប្រជុំទទួលស្គាល់ ឬឯកភាព ។ លោកស្រីបានបន្ថែមថា ធ្វើជាប្រធានក្រុមប្រឹក្សាឃុំ ត្រូវមានផែនការច្បាស់លាស់ ត្រូវមានភាពក្លាហាន បើនិយាយត្រូវតែធ្វើ ទោះជាកិច្ចការនោះពិបាកក៏ដោយ ដើម្បីដោះស្រាយជូនប្រជាពលរដ្ឋឱ្យទាន់ពេលវេលា។

លោកស្រីបន្តថា ការងារទទួលបានជោគជ័យ ក៏អាស្រ័យដោយមានការផ្តល់ឱកាសជំរុញ និងលើកទឹកចិត្តយោបល់ពីក្រុមគ្រួសារ និងថ្នាក់ដឹកនាំគាំទ្រ ផ្តល់ជាកម្លាំងចិត្ត និងមានការចូលរួមពីមន្ត្រីនៅក្រោមឱវាទផងដែរ ។

លោកស្រីបានលើកឡើងថា សមិទ្ធិផលរយៈពេល២អាណត្តិដែលនាងខ្ញុំដឹកនាំនេះ រួមមាន៖ អណ្តូងទឹកស្អាត ពីផ្លូវគ្រួសក្រហម មកជាផ្លូវប៊ូតុងចំនួន ៣ខ្សែ ដែលមានប្រវែងជាង ១.០០០ម៉ែត្រ វត្តអារាម ព្រះវិហារសាសនា ។

លោកស្រីបានបន្ថែមទៀតថា ក្រៅពីការងារមនុស្សធម៌ និងការងារអភិវឌ្ឍន៍ លោកស្រីបានផ្សព្វផ្សាយពីគោល-នយោបាយភូមិឃុំមានសុវត្ថិភាពជាប្រចាំ នៅតាមភូមិ និងបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ដូចជា អ្នកគ្រប់អាយុឱ្យមកធ្វើអត្តសញ្ញាណប័ណ្ណ ធ្វើសំបុត្រកំណើត ការចុះសំបុត្រអាពាហ៍ពិពាហ៍...។ល។

លោកស្រីក៏បានលើកឡើងដែរថា ទន្ទឹមនិងការងារជោគជ័យ ក៏មានបញ្ហាប្រឈមខ្លះៗផងដែរ គ្រាន់តែមិនធ្ងន់ធ្ងរ។

លោកស្រីសូមផ្តាំដល់ស្ត្រីទាំងឡាយ ចង់ក្លាយជាថ្នាក់ដឹកនាំល្អទទួលបានជោគជ័យ មានកត្តា២គឺ កត្តាអត្តនោម័ត និងសត្យានុម័ត ។

លោកស្រី **ថន ឥមស្រ៊ន់** ប្រធានមន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំ បានមានប្រសាសន៍ថា៖ ថ្នាក់ដឹកនាំជាស្ត្រីនៅតាមឃុំស្រុកទាំងអស់ គឺដំបូងសុទ្ធតែកើតចេញពីការស្ម័គ្រចិត្ត និងលទ្ធផលការងារល្អជាមួយថ្នាក់លើ ហើយមានគុណសម្បត្តិគ្រប់គ្រាន់ ដោយឆ្លងកាត់ការជម្រុញ និងលើកទឹកចិត្តចូលរួមបណ្តុះបណ្តាលសមត្ថភាព តាមរយៈវគ្គបណ្តុះបណ្តាលជាដើម ។

ជាចុងក្រោយលោកស្រីប្រធានសូមផ្តល់អនុសាសន៍៖ ដើម្បីក្លាយខ្លួនជាថ្នាក់ដឹកនាំមួយរូប ស្ត្រីត្រូវមានការប្រកួតប្រជែងទាំងចរិយាសម្បត្តិ និងឥរិយាបទល្អ មានធនធានចំណេះដឹងគ្រប់គ្រាន់ មានការទទួលខុសត្រូវខ្ពស់ មានផែនការច្បាស់លាស់ ចេះយោគយល់អធ្យាស្រ័យ រួមសុខរួមទុក្ខជាមួយមន្ត្រីក្រោមឱវាទ ដឹកនាំដោយមានតម្លាភាព ហើយក្នុងបរិបទសម័យបច្ចេកវិទ្យា និងឌីជីថល ស្ត្រីត្រូវចេះប្រើប្រាស់ហ្វេសប៊ុក និងតេលេក្រាមជាចាំបាច់៕

*សោភា*

# «ស្ត្រីជោគជ័យក្នុងវិស័យដាំដំណាំម្អម»





អ្នកស្រី **គ សុភ័ណ្ណា** ជាប្រជាកសិករ នៅភូមិទ័ពស្តេច ឃុំធាយ ស្រុកបាភ្នំ។ អ្នកស្រីបានប្រាប់ថា កាលពីមុនគ្រួសាររបស់គាត់ជាអ្នកធ្វើស្រែ ប៉ុន្តែប្រាក់ចំណូលពីការធ្វើស្រែនេះ មិនអាចផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃបានគ្រប់គ្រាន់នោះទេ ដូច្នេះក៏សម្រេចចិត្តទៅធ្វើជាកម្មការនីនៅរោងចក្រ ក្នុងទីក្រុងភ្នំពេញ ដោយផ្ញើកូនឱ្យរស់នៅជាមួយបងស្រី។ ថ្វីត្បិតតែប្រាក់ចំណូលពីការធ្វើការច្រើនជាងការធ្វើស្រែ ប៉ុន្តែអ្នកស្រីត្រូវឃ្លាតឆ្ងាយពីកូនមិនមានពេលវេលាមើលថែកូន និងឱ្យកូនទៅសាលារៀនមិនបានត្រឹមត្រូវ។

អ្នកស្រីបានរៀបរាប់បន្តថា ដោយមើលឃើញគេដាំម្អម ហើយទទួលបានប្រាក់ចំណូលច្រើនគួរសម  អ្នកស្រីក៏មានគំនិតប្តូរមុខរបរពីការធ្វើស្រែ និងធ្វើការជាកម្មការនីនៅរោងចក្រមកដាំម្អមវិញ។

អ្នកស្រីក៏បានបញ្ជាក់ថា បន្ទាប់ពីការចាប់យកការដាំម្អមនៅលើផ្ទៃដី ២.៥ ហិកតា គ្រួសាររបស់គាត់មានសេដ្ឋកិច្ចរឹងមាំដែលមិនបារម្ភពីការចំណាយប្រចាំថ្ងៃ និងអាចដកទុកដើម្បីសន្សំបានមួយចំនួនទៀតទៅតាមការលក់បានតិចឬច្រើន។ ដោយសារតែបញ្ហាជំងឺកូវីដ-១៩ ការកម្មង់របស់ឈ្មួញក៏មានការកាត់បន្ថយ សព្វថ្ងៃស្រែម្អមរបស់អ្នកស្រីដាំនៅលើផ្ទៃដី១.៥ហិកតា ក៏បន្តែប្រាក់ចំណូលដែលបានមកពីមុខរបរនេះ នៅតែអាចឱ្យគ្រួសារដោះស្រាយជីវភាពប្រចាំថ្ងៃបានសមរម្យ ហើយអ្វីដែលគាត់សប្បាយចិត្តនោះគឺគ្រួសាររបស់គាត់បានរស់នៅជួបជុំគ្នា មានពេលវេលាមើលថែកូនគ្រប់គ្រាន់ និងឱ្យកូនទៅសាលារៀនបានត្រឹមត្រូវ។

លោកស្រី **ខិន ពៅ** អតីតប្រធានមន្ទីរកិច្ចការនារីខេត្តព្រៃវែង បានមានប្រសាសន៍ថា៖ ពាក់ព័ន្ធ នឹងការពង្រឹងភាពអង់អាច ផ្នែកសេដ្ឋកិច្ច ក៏ដូចជាការលើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅក្នុងវិស័យកសិកម្ម មន្ទីរកិច្ចការនារីតែងតែបញ្ជ្រាបការអប់រំតាមរយៈវេទិកាផ្សេងៗ របស់មន្ទីរ ២-៣ដងក្នុង១ឆ្នាំ ក្នុងគោលបំណងផ្តល់ចំណេះដឹង និងជំរុញឱ្យស្ត្រី មានឯករាជ្យក្នុងផ្នែកសេដ្ឋកិច្ច។ ទន្ទឹមនឹងនេះ មន្ទីរកិច្ចការនារី ក៏បានសហការជាមួយមន្ទីរកសិកម្ម ក្នុងការអនុវត្តគម្រោងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ តាមរយៈការគាំទ្រថវិកាពីរាជរដ្ឋាភិបាល និងADB ដោយផ្តល់វគ្គបណ្តុះបណ្តាលស្តីពី យេនឌ័រ អាហារូបត្ថម្ភ បច្ចេកទេសកសិកម្ម ការចងក្រងក្រុម និងការប្រើប្រាស់ទុនកម្ចីដើម្បីបង្កើតមុខរបរជាដើម។

លោកស្រីបានបន្ថែមទៀតថា នៅក្នុងគម្រោងនេះក៏មានបង្កើតជាក្រុមកែលំអរជីវភាពផលិតវត្ថុអនុស្សាវរីយ៍ និងរបស់ប្រើប្រាស់ដែលធ្វើអំពីផ្តៅ និងបានទទួលការគាំទ្រពីគណៈកម្មការខេត្ត ក្នុងការបង្កើតភូមិ១ ផលិតផល១ ដើម្បីពង្រីកទីផ្សារផលិតផល។

លោក **ព្រំ សុផាត** ប្រធានការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន ស្រុកបាភ្នំ បានមានប្រសាសន៍ថា តាមរយៈគម្រោង PADI ការិយាល័យកសិកម្ម បានធ្វើការងារជាច្រើនក្នុងការលើកកម្ពស់សមភាពយេនឌ័រ ក្នុងវិស័យកសិកម្ម រួមមានការផ្តល់វគ្គបណ្តុះបណ្តាលស្តីពី យេនឌ័រ អាហារូបត្ថម្ភ និងបច្ចេកទេសកសិកម្ម។ ទន្ទឹមនឹងនោះក៏មានការចងក្រង ក្រុមស្ត្រីឱ្យក្លាយជាអ្នកដឹកនាំសហគមន៍ អ្នកបច្ចេកទេសកសិកម្ម និងគ្រូបណ្តុះបណ្តាលផ្នែកបច្ចេកទេសកសិកម្ម។ គម្រោងក៏មានជាកញ្ចប់ថវិកា សម្រាប់ផ្តល់កម្ចីដល់ គ្រួសារដែលបានចងក្រងក្រុម និងមានបំណងចង់បង្កើតមុខរបរ តាមរយៈការវាយតម្លៃពីក្រុមប្រឹក្សាភិបាល

***តទៅទំព័រ៤២***

តមកពីទំព័រ៤១ **«ស្ត្រីជោគជ័យក្នុងវិស័យដាំដំណាំម្លូ...»**

ជាអ្នកសម្រេចក្នុងការផ្ដល់ទុន។ ជាលទ្ធផលមានស្ត្រីដែលបានទទួលការបណ្ដុះបណ្ដាលមួយចំនួនក្លាយជាពេទ្យសត្វភូមិ អ្នកដឹកនាំសហគមន៍ និងមានគ្រួសារជាស្ត្រីជាច្រើនទទួលបានជោគជ័យក្នុងការដាំដំណាំស្រូវ ការដាំបន្លែ និងការចិញ្ចឹមសត្វ។ មានគ្រួសារខ្លះអាចផ្គត់ផ្គង់បន្លែសម្រាប់ប្រើប្រាស់នៅស្រុកបាភ្នំ។

លោកបានបន្តទៀតថា ក្នុងនាមការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន លោក **ព្រំ សុផាត** បានលើកទឹកចិត្តឱ្យប្រជាពលរដ្ឋនៅក្នុងស្រុកបាភ្នំ ចាប់យកមុខរបរកសិកម្ម ដើម្បីបង្កើនប្រាក់ចំណូលនៅក្នុងគ្រួសារមានមុខរបរពិតប្រាកដ និងជៀសវាងការធ្វើចំណាកស្រុកដែលប្រឈមនឹងបញ្ហាផ្សេងៗ។

អ្នកស្រី **ឥ សុភ័ណ** បានប្រាប់អ្នកយកព័ត៌មានយើងបន្ថែមទៀតថា ទោះបីជាមានឈ្មួញ ត្រូវការកម្មង់ម្លូក្នុងចំនួនប៉ុន្មានក៏គាត់អាចផ្គត់ផ្គង់បានដែរ ព្រោះគាត់មានដីដែលទុកគល់ម្លូមានអ្នកថែទាំនិងអ្នកកាត់ម្លូគ្រប់គ្រាន់។ សម្រាប់ឈ្មួញដែលត្រូវការកម្មង់អាចទំនាក់ទំនងតាមរយៈលេខ ទូរស័ព្ទ ០៩៦ ៣៧២ ៨២៨៣ និង ០៧០ ៥៥៤ ២៩២ ឬមកដល់ស្រែម្លូផ្ទាល់ ស្ថិតនៅក្នុង ភូមិទ័ពស្ដេច ឃុំផាយ ស្រុកបាភ្នំ ខេត្តព្រៃវែង៕ ***គន្ធា***

---

តមកពីទំព័រ៣៩
**« សមាគមស្ត្រីកែច្នៃផលិតផល......»**

សម្រាប់ផលិតផលគ្រឿងសមុទ្រកែច្នៃ ដោយរៀបចំឱ្យមានជាកន្លែងដាក់លក់ផលិតផលជាក់លាក់ រៀបចំការវេចខ្ចប់មានស្តង់ដារ និងតម្លៃសមរម្យ។

ចំណែកក្រុមស្ត្រី ដែលបានចងក្រងបង្កើតសមាគមស្ត្រីកែច្នៃផលិតផលគ្រឿងសមុទ្រ (មណ្ឌលទីផ្សារទំនប់រលក) ក៏បានមានប្រសាសន៍ថាមណ្ឌលទីផ្សារទំនប់រលកមានទីតាំងនៅក្រុមពភូមិ២ឃុំទំនប់រលកស្រុកស្ទឹងហាវខេត្តព្រះសីហនុ មានសមាជិកចំនួន១៦នាក់ ក្នុងនោះមានសមាជិកចូលភាគហ៊ុន៥នាក់ និងអ្នកផលិត ១១នាក់។ ប្រភពទុនទទួលបានពីសមាជិក និងមានផលិតផលសម្រាប់ដាក់លក់ដូចជា ផ្អកកាកឹម ត្រីងៀតក្តចិន ត្រីងៀតកាកឹម បង្គាក្រៀម មឹកក្រៀម ទឹកត្រី និងកាពិ។ ផលិតផលដែលបានកែច្នៃ ប្រកបដោយគុណភាពខ្ពស់ គ្មានជាតិគីមី មានអនាម័យល្អ ។

ក្រុមស្ត្រីទទួលបានការបណ្ដុះបណ្ដាលអាជីវកម្មខ្នាតតូចពីអង្គការ ARD និងរបៀបកែច្នៃអនាម័យ និងធ្វើស្លាកសញ្ញាដោយអង្គការមេរតក។ ពួកគាត់ក៏មានសំណូមពរឱ្យជួយផ្សព្វផ្សាយ និងជួយផ្ដល់មតិយោបល់ដល់មណ្ឌលទីផ្សារឃុំទំនប់រលក ដើម្បីឱ្យផលិតផលសហគមន៍មានចរន្តនៅលើទីផ្សារ និងមានការទទួលស្គាល់ និងគាំទ្រពីអតិថិជនកាន់តែច្រើន៕ ***គន្ធា***

---

តមកពីទំព័រ៣៨ **«ស្ត្រីក្នុងភាពជាអ្នកដឹកនាំ....»**

ចំណាយពេលវេលាទាំងកម្លាំងចិត្ត និងកម្លាំងកាយ ក្នុងការបម្រើការងារជូនប្រជាពលរដ្ឋក្នុងខេត្តមណ្ឌលគិរី ជាពិសេសទាក់ទងវិស័យកិច្ចការនារី ។ លោកជំទាវបន្តថា ក្នុងនាមក្រុមប្រឹក្សាខេត្ត មានភារកិច្ចផ្ដល់យោបល់ និងលើកអនុសាសន៍ជូនគណៈអភិបាលខេត្ត គណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាខេត្ត លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារ ដែលស្ថិតនៅក្នុងអំណាចមុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ។

លោកជំទាវបានបន្ថែមថា រាល់កិច្ចប្រជុំ តែងស្នើសុំទៅមន្ទីរអង្គភាពពាក់ព័ន្ធ ត្រូវរៀបចំដាក់បញ្ចូលស្ត្រីជាថ្នាក់ដឹកនាំនៅគ្រប់កម្រិតនៅក្នុងស្ថាប័ននីមួយៗ បើមន្ទីរណាគ្មានស្ត្រីជាអនុប្រធានមន្ទីរ រៀបចំតែងតាំងជាបន្តបន្ទាប់ ។ លោកជំទាវក៏បានបន្ថែមទៀតថា ដោយឡែកតាមរយៈកិច្ចប្រជុំឃុំ-សង្កាត់យើងបានជម្រុញ និងលើកទឹកចិត្តឱ្យយកចិត្តទុកដាក់ជាមួយបញ្ហាស្ត្រី ជាពិសេស ស្ត្រីមានផ្ទៃពោះ និងត្រូវសម្រាលកូននៅមណ្ឌលសុខភាព ។ មិនតែប៉ុណ្ណោះរាល់ការលើកផែនការសកម្មភាពត្រូវតែឆ្លើយតប និងផ្ដល់ផលប្រយោជន៍ដល់ស្ត្រី និងកុមារ។ ម្យ៉ាងទៀតការចូលរួមរបស់ស្ត្រីពិតជាមានសារៈសំខាន់ណាស់ក្នុងការរួមចំណែកកសាងប្រទេសជាតិទាំងមូលឱ្យឈានទៅរកការអភិវឌ្ឍជានិរន្តរ៍៕ ***សោភា***

# ការតស៊ូរបស់ស្ត្រីក្នុងមុខរបរសាឡនបែបលក្ខណៈគ្រួសារ

ក្មួយស្រី **ហាន ម៉េងហួយ** មានអាយុ ១៧ឆ្នាំ ឈប់រៀនត្រឹមថ្នាក់ទី៥ មានបងប្អូន ២នាក់ នៅភូមិតំបែរ ឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ឪពុកម្តាយជាអ្នកធ្វើស្រែបាននិយាយថា បច្ចុប្បន្ននាងខ្ញុំប្រកបមុខរបរសាឡន ដោយស៊ីភាគរយពីមេជាង។ មុននឹងមានមុខរបរដូចសព្វថ្ងៃ នាងខ្ញុំបានរៀនផាត់មុខ និងធ្វើសក់នេះដោយសារមន្ត្រីកិច្ចការនារីឃុំបានយកនាងខ្ញុំទៅផ្ញើជាមួយនឹងមេជាងសាឡន ដើម្បីទទួលបានការបង្ហាត់បង្រៀន និងរៀនសំអាងការរយៈពេល ១ឆ្នាំ។ **ម៉េងហួយ**បានរៀបរាប់ថា ពេលខ្លះមានអតិថិជនមកធ្វើសក់ច្រើនរកពេលញ៉ាំបាយគ្មាន។ ក្មួយស្រីបន្តថា ទៅថ្ងៃអនាគត នាងខ្ញុំមានបំណងផ្តាច់ចេញពីមេជាង ដើម្បីទៅបើកហាងខ្លួនឯង។

ជាចុងក្រោយនាងខ្ញុំសូមផ្តាំដល់ក្មេងស្រីដទៃទៀតថា យើងត្រូវតស៊ូរាល់ការលំបាកទាំងឡាយ ជំនះគ្រប់ឧបសគ្គក្នុងការប្រកបអាជីវកម្ម ទោះតូចក្តី ធំក្តី ត្រូវតែមានខ្លួនឯង។

អ្នកស្រី **សេង សុណារា** អាយុ៤៦ឆ្នាំ រៀនថ្នាក់ទី២ មានកូន ៤នាក់ ជាស្ត្រីមេម៉ាយធ្លាប់រងនូវអំពើហិង្សាក្នុងគ្រួសារ នៅឃុំតំបែរ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ បាននិយាយថា មុននឹងមានអាជីពច្បាស់លាស់ និងជីវភាពប្រសើរជាងមុន ខ្ញុំមានដំណើររឿងកំសត់ជូរជត់ណាស់ ត្រូវប្តីធ្វើបាបទាំងចិត្តទាំងកាយ ។ នៅឆ្នាំ២០១៧ ក៏បានចូលរៀនផ្នែកសាឡន នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេល ៤-៥ខែ ដោយពេលនោះរៀនបណ្តើរអនុវត្តបណ្តើរ ពេលមានម៉ូយមកធ្វើសក់ ឬផាត់មុខ ធ្វើក្រចក គឺខ្ញុំមិនយកកម្រៃទេ។ អ្នកស្រីរៀបរាប់ទាំងទឹកភ្នែកថា ដំបូងមានប្រាក់ត្រឹមតែ ១០ម៉ឺនរៀលគត់ សល់ពីមើលជម្ងឺខ្លួនសម្រាប់ទិញឧបករណ៍ល្មមៗ ដើម្បីបើកកន្លែងរកស៊ី។

អ្នកស្រីបន្តថា ដោយសារខ្ញុំព្យាយាម មានទឹកដៃល្អ ធ្វើឱ្យភ្ញៀវពេញចិត្ត ទើបបានបើកកន្លែងអ៊ុតសក់នៅនឹងផ្ទះតែម្តង ពេលខ្លះម៉ូយមកច្រើនពេក ១ថ្ងៃញ៉ាំបាយបានតែ ១ពេលក៏មាន (រដូវបុណ្យ-ការ) ចំពោះប្រាក់ចំណូលបានគួរសម ។

អ្នកស្រីបន្ថែមថា ដោយមានការលើកទឹកចិត្តពីកូនៗ ទៅថ្ងៃអនាគតនាងខ្ញុំមានបំណងចង់ពង្រីកមុខរបរនេះឱ្យធំជាងហ្នឹង ដោយសារបច្ចុប្បន្នជួលផ្ទះគេនៅឡើយ ណាមួយកូនៗកំពុងរៀននៅមហាវិទ្យាល័យឯរាជធានីភ្នំពេញ ឆ្នាំទី១ និងទី២។ ជាចុងក្រោយអ្នកស្រីសូមផ្តាំដល់ស្ត្រីទាំងឡាយថា ប្រសិនបើជួបរឿងហិង្សាដូចនាងខ្ញុំ មិនត្រូវស៊ូទ្រាំលំបាកឡើយ ត្រូវតែចាកចេញ ហើយត្រូវមានភាពក្លាហាន រឹងមាំ ក្នុងនាមជាស្ត្រីមិនខ្វះទេមុខរបរ ត្រូវមានការតស៊ូជានិច្ច។



លោកស្រី **ថន គឹមស្រ៊ន់** ប្រធានមន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំបានមានប្រសាសន៍ថា៖ មន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំបានលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីតាមសហគមន៍ តាមរយៈការអនុវត្តគម្រោង និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលឧបត្ថម្ភដោយអង្គការJICA ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលជំនាញដល់ស្ត្រី ដោយសមស្របតាមតម្រូវការទីផ្សារ ដូចជា ចិញ្ចឹមមាន់ ដាំបន្លែ កែច្នៃអាហារ ដេរប៉ូប ប៉ាក់គ្រប់ម៉ូដ សាឡន ជាដើម រួមទាំងធ្វើការផ្សព្វផ្សាយតាមទូរទស្សន៍ និងវិទ្យុខេត្តត្បូងឃ្មុំដល់សហគមន៍ និងបង្កើតក្រុមពហុវិស័យក្នុងការបង្កើនសមត្ថភាពជូនដល់ស្ត្រី ដូចជា សេវាគាំពារផ្លូវច្បាប់ ជំនួញជួញដូរទំនាក់ទំនង នឹងអង្គការដៃគូ។

ជាចុងក្រោយលោកស្រីសូមផ្តល់ជាអនុសាសន៍ដល់ស្ត្រីទាំងឡាយ ត្រូវមានការប្រកួតប្រជែង ទាំងចរិយាសម្បត្តិ និងឥរិយាបទល្អ មានធនធាន ចំណេះដឹងគ្រប់គ្រាន់ ហើយក្នុងបរិបទសម័យបច្ចេកវិទ្យា និងឌីជីថល ស្ត្រីត្រូវចេះប្រើប្រាស់ហ្វេសប៊ុក និងតេលេក្រាមជាចាំបាច់ក្នុងការប្រកបអាជីវកម្មផ្សេងៗ ។ល។៚ ***សោភា***

# សិស្សស្រីឆ្នើមកម្ពុជាទទួលមេដាយ ១៦គ្រឿង នៅសហរដ្ឋអាមេរិក




អបអរសាទរសិស្សស្រីឆ្នើម ៥រូប នៃសាលាអន្តរជាតិ អាយ ស៊ី អេស បានឈ្នះមេដាយចំនួន ១៦គ្រឿងក្នុងកម្មវិធីពានរង្វាន់សិស្សពូកែពិភពលោក វគ្គផ្តាច់ព្រ័ត្រពានជើងឯក (Tournament of Champions) នៅឯសកលវិទ្យាល័យ Yale ទីក្រុង ញូវយ៉ក សហរដ្ឋអាមេរិក លើមុខវិជ្ជា **១**.ពិភាក្សា និងវែកញែក **២**.វិទ្យាសាស្ត្រ **៣**.បច្ចេកវិទ្យា **៤**.ប្រវត្តិសាស្ត្រ **៥**.សិក្សាសង្គម និង**៦**.អក្សរសាស្ត្រភាសាអង់គ្លេស ដោយទទួលបានមេដាយចំនួន **១៦**គ្រឿង មេដាយមាស **១៣**គ្រឿង និងមេដាយប្រាក់ **៣** គ្រឿងកាលពីពេលថ្មីៗនេះ៖

-**ចាច់ ស៊ីលីណា**: មេដាយមាស ៥គ្រឿង និងមេដាយប្រាក់ ១គ្រឿង

- **ម៉ារ ឋរិយ៉ា** : មេដាយមាស ២គ្រឿង និងមេដាយប្រាក់ ១គ្រឿង

- **ព្រំ សុទ្ធិ សុភបញ្ញាវឌ្ឍ** : មេដាយមាស ២គ្រឿង និងមេដាយប្រាក់ ១គ្រឿង

- **មាន ឯមមុនីនាថ** : មេដាយមាស ២គ្រឿង

- **នេត មុនីនាថ** : មេដាយមាស ២គ្រឿង

កម្មវិធីពានរង្វាន់សិស្សពូកែពិភពលោក ( World Scholar's



Cup ២០២៣) មានសិស្សជាង ១.៥០០នាក់ ពីបណ្តាប្រទេសចំនួន ៨២ចូលរួម ដែលជាកម្មវិធីលំដាប់ថ្នាក់ពិភពលោកមួយ ដែលបានរៀបចំឡើងក្នុងគោលបំណងទាក់ទាញសិស្សានុសិស្សឱ្យពួកគាត់មានភាពក្លាហាន បង្ហាញនូវគំនិតបញ្ញា ស្មារតី ព្រមទាំងការពង្រឹងសមត្ថភាព ជុំវិញបញ្ហាដែលកើតមាននៅជុំវិញខ្លួនរបស់ពួកគេក្នុងពេលបច្ចុប្បន្ន និងមានកិត្តិយសបង្ហាញមុខនៅលើឆាកអន្តរជាតិផងដែរ៕




FACEBOOK: ICS Internaional School


STPM
អបអរសាទរ
VICTOR
ក្រុមកីឡាការិនីវាយសីកម្ពុជា
លឿង ម៉ាលីនិច្ច និង សុខ សុម៉ាលីតា
ដែលបានឈ្នះមេដាយមាស ក្នុងព្រឹត្តិការណ៍
ប្រកួតកីឡា វាយសីជើងឯកយុវជនអាស៊ីអាគ្នេយ៍
(BA Sea Regional Junior Championship) ឆ្នាំ២០២៣
លើវិញ្ញាសាវាយគូនារី អាយុក្រោម ១៥ឆ្នាំ
ពហុកីឡដ្ឋានជាតិមរតកតេជោ ព្រឹកថ្ងៃទី៣ វិច្ឆិកា ២០២៣

# គំនូរបំព្រួញស្តីពី
# «យុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី ១»
# ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព
# និង ចីរភាព : កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេច
# ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

